# ព្រឹទ្ធសភា

# SENATE MAGAZINE

## ទស្សនាវដ្ដីខែធ្នូ




លេខ ៣០២ ឆ្នាំទី២៥ ព.ស.២៥៦៩ គ.ស.២០២៥
Issue 302 Volume 25 BC 2569 BE 2025

# មាតិកា

## សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា ( ១-២៤ )


- សម្ដេចតេជោ និងឯកឧត្តម Bui Thanh Son ពេញចិត្តចំពោះការកើនឡើងជាបន្តបន្ទាប់នូវទំហំពាណិជ្ជកម្មរវាងកម្ពុជានិងវៀតណាម ហើយនឹងអាចសម្រេចបាន ២០ពាន់លានដុល្លារអាម៉េរិកនាពេលខាងមុខ ........ ១
- សម្ដេចតេជោ៖ កម្ពុជាស្វាគមន៍ចំពោះការវិលត្រឡប់របស់កាណាដា មកបើកនិវេសនដ្ឋានស្ថានទូតប្រចាំនៅកម្ពុជា........ ២
- ប្រទេសឆែក នឹងជម្រុញបន្ថែមការវិនិយោគលើវិស័យកសិកម្មនៅកម្ពុជា ........ ៣
- កម្ពុជា-ចិន ជាមិត្តដែកថែប និងជាសហគមន៍វាសនារួមគ្រប់រដូវកាល ក្នុងយុគសម័យថ្មីដែលជាទំនាក់ទំនងដ៏ស៊ីជម្រៅ........ ៤
- ឯកឧត្តម **អ៊ុច បូររិទ្ធ** អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៤ ........ ៥
- ឯកឧត្តម **អ៊ុច បូររិទ្ធ** អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៥ ........ ៧
- ឯកឧត្តម **អ៊ុច បូររិទ្ធ** អញ្ជើញដឹកនាំការបន្តសម័យប្រជុំលើកទី៤ ដើម្បីពិនិត្យហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ចំនួន៣ ........ ៨
- ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា អញ្ជើញប្រគល់ផ្ទះ និងនាំយកអំណោយចែកជូនគ្រួសារក្រីក្រ នៅស្រុកកងមាស និងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ........ ១២
- ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា អញ្ជើញចុះសួរសុខទុក្ខ និងនាំយកអំណោយជូនកងទ័ពសមរភូមិមុខ និងគ្រួសារយុទ្ធជន នៅខេត្តឧត្តរមានជ័យ និងខេត្តបាត់ដំបង ........ ១៤
- ឯកឧត្តម **អ៊ុច បូររិទ្ធ** អញ្ជើញចុះសួរសុខទុក្ខវីរយុទ្ធជនរងរបួសក្នុងពេលប្រយុទ្ធជាមួយកងទ័ពឈ្លានពានថៃ ដែលកំពុងសម្រាកព្យាបាលនៅតាមមន្ទីរពេទ្យជាតិចំនួន៥ ក្នុងរាជធានីភ្នំពេញ ........ ១៦
- គោលនយោបាយអន្តរជាតិរបស់កម្ពុជា គឺកសាងមិត្ត មិនបង្កើតសត្រូវឈរលើគោលការណ៍ច្បាប់ និងភាពត្រឹមត្រូវ........ ១៨
- ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** លើកទឹកចិត្តមូលនិធិចិនដើម្បីសន្តិភាពនិងការអភិវឌ្ឍកសាងភូមិគំរូបន្ថែមទៀត នៅតាមភូមិភាគទាំង៨ ដោយផ្ដោតលើការអប់រំកុមារ និងសុខភាព........ ១៩
- សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ ........ ២០








## សកម្មភាពគណៈកម្មការនានារបស់ព្រឹទ្ធសភា ( ២៥-៥៥ )


- ឯកឧត្តម **ម៉ម ប៊ុននាង** អញ្ជើញនាំយកអំណោយរបស់ព្រឹទ្ធសភាប្រគល់ជូនរដ្ឋបាលខេត្តតាកែវ និងខេត្តកំពត........ ២៥
- ក្រុមសមាជិកាព្រឹទ្ធសភា អញ្ជើញជួបសំណេះសំណាល និងនាំយកចង្ក្រានសន្សំសំចៃថាមពលចែកជូនប្រជាពលរដ្ឋក្នុងស្រុកប្រាសាទបល្ល័ង្ក ........ ២៧
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ អញ្ជើញនាំយកអំណោយជាគ្រឿងឧបភោគ បរិភោគ ចែកជូនជនភៀសសឹកចំនួន៣ស្រុក ក្នុងខេត្តកោះកុង ........ ២៩
- គណៈប្រតិភូគណៈកម្មការទី៨ និងក្រុមសមាជិកាព្រឹទ្ធសភា អញ្ជើញសួរសុខទុក្ខ និងនាំយកអំណោយគ្រឿងឧបភោគ បរិភោគ សម្ភារៈប្រើប្រាស់ និងថវិកាប្រគល់ជូនវីរកងទ័ពប្រចាំសមរភូមិមុខ និងវីរកងទ័ពរងរបួសកំពុងសម្រាកព្យាបាលជំងឺ នៅខេត្តព្រះវិហារ និងខេត្តកំពង់ធំ ........ ៣១
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ អញ្ជើញនាំយកអំណោយជាគ្រឿងឧបភោគ បរិភោគ ចែកជូនជនភៀសសឹក នៅស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ........ ៣៣
- កិច្ចប្រជុំគណៈកម្មការទាំង១០ ក្រុមភូមិភាគ និងក្រុមនានានៃព្រឹទ្ធសភា........ ៣៥
- ការទទួលពាក្យបណ្ដឹង........ ៤១
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្ដាភូមិភាគទាំង៨ ........ ៤២
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស ........ ៥០
- សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ ........ ៥១


## សកម្មភាពអគ្គលេខាធិការដ្ឋាន ( ៥៦-៦៤ )


- ឯកឧត្តម **ឡាយ សំកុល** អញ្ជើញជាគណៈអធិបតីក្នុងពិធីបិទសិក្ខាសាលាស្ដីពី «កិច្ចការសភា»........ ៥៦
- ឯកឧត្តម **ឡាយ សំកុល** អញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែវិច្ឆិកា និងកំណត់ទិសដៅការងារខែធ្នូ ឆ្នាំ២០២៥........ ៥៨
- ឯកឧត្តម **ខេង សិទ្ធិគុណ** អញ្ជើញជាគណៈអធិបតីក្នុងពិធីធ្វើបាឋកថាស្ដីពី អភិបាលកិច្ចឌីជីថល........ ៦០
- សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ........ ៦២



**អ្នកគ្រប់គ្រងទូទៅ**

ឯកឧត្តម ឡាយ សំកុល

**អ្នកសម្របសម្រួលខ្លឹមសារ និងអក្ខរាវិរុទ្ធ**

ឯកឧត្តម ខេង សិទ្ធិគុណ

ឯកឧត្តម ជាម សុផលមករា

ឯកឧត្តម ជួន ណា

លោក ជួន សុខជី

លោក ទេព មករា

លោក កុក វ៉ៃ

លោក សុង សុខភារ័ត្ន

**អ្នកគ្រប់គ្រងផ្ទាល់**

លោក ទេព មករា

**ក្រុមអ្នកយកព័ត៌មាន**

ការិយាល័យព័ត៌មាន

**ការីកុំព្យូទ័រ**

លោក ជុំ ច័ន្ទរតនា

លោក ធុន គីមជី

លោកស្រី សុខ សុជាតា


### ក្របមុខ

*- សម្ដេចតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ផ្ដល់ប្រឹក្សាយុទ្ធសាស្ត្រ ដើម្បីបុព្វហេតុការពារបូរណភាពទឹកដីពីការឈ្លានពានរបស់ថៃ។*

*- ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា អញ្ជើញនាំយកអំណោយជូនកងទ័ពសមរភូមិមុខ និងគ្រួសារយុទ្ធជន នៅខេត្តបាត់ដំបង។*

*- ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា អញ្ជើញចុះសួរសុខទុក្ខបងប្អូនជនភៀសសឹក នៅវត្តសុវណ្ណគិរី ស្រុករវៀង ខេត្តព្រះវិហារ និងនៅវត្តអូរប្រាសាទ ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ។*

*- ការហែក្បួនដោយថ្មើរជើង ដើម្បីស្វែងរកសន្តិភាពរបស់ប្រជាពលរដ្ឋកម្ពុជា៕*

# សម្តេចតេជោ និងឯកឧត្តម Bui Thanh Son ពេញចិត្តចំពោះការកើនឡើងជាបន្តបន្ទាប់នូវទំហំពាណិជ្ជកម្មរវាងកម្ពុជានិងវៀតណាម ហើយនឹងអាចសម្រេចបាន ២០ពាន់លានដុល្លារអាមេរិកនាពេលខាងមុខ

ក្នុងឱកាសជំនួបសម្តែងការគួរសមរបស់ឯកឧត្តម Bui Thanh Son ឧបនាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ជាមួយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានព្រឹទ្ធសភា នាព្រឹកថ្ងៃសុក្រ ទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៥ **សម្តេចតេជោ** និង**ឯកឧត្តមឧបនាយករដ្ឋមន្ត្រីវៀតណាម** បានវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនងនិងសហប្រតិបត្តិការដ៏ល្អប្រពៃរវាងប្រទេសកម្ពុជានិងវៀតណាម ទាំងក្នុងក្របខ័ណ្ឌអង្គការនីតិប្បញ្ញត្តិនិងនីតិប្រតិបត្តិ ដែលមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ជាពិសេសទំនាក់ទំនងពាណិជ្ជកម្មរវាងប្រទេសទាំងពីរ ដែលគិតត្រឹមតែរយៈពេល ៩ខែ ឆ្នាំ២០២៥ មានជាង៩ពាន់លានដុល្លារ ហើយសង្ឃឹមថា នឹងអាចសម្រេចបាន២០ពាន់លានដុល្លារ នាពេលខាងមុខ។



*ឯកឧត្តម Bui Thanh Son និងសម្តេចតេជោ ហ៊ុន សែន*

ភាគីទាំងពីរ បានលើកឡើងអំពីការរក្សាបាននូវសន្តិសុខ ការប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែននិងសហប្រតិបត្តិការដ៏ល្អក្នុងការដោះស្រាយបញ្ហានៅតាមបណ្តោយព្រំដែន ដើម្បីធ្វើយ៉ាងណាឱ្យព្រំដែននៃប្រទេសកម្ពុជានិងវៀតណាម មានសុខសន្តិភាពនិងធ្វើឱ្យប្រជាជនរស់នៅកាន់តែមានភាពល្អប្រសើរ។

នៅក្នុងជំនួបនោះ **សម្តេចតេជោ** បានលើកឡើងអំពីការផ្សារភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធរវាងប្រទេសទាំងពីរ ដែលអំណោយផលដល់ការធ្វើសហប្រតិបត្តិការពាណិជ្ជកម្មរវាងប្រទេសទាំងពីរឱ្យមានភាពល្អប្រសើរ ដូចនឹងបំណងរបស់**សម្តេចតេជោ**។ **សម្តេច**បានមានប្រសាសន៍អំពីគម្រោងដែលប្រទេសទាំងពីរ នឹងធ្វើពិធីសម្ពោធបើកច្រកព្រំដែនអន្តរជាតិម៉ឺនជ័យជាមួយគ្នា នៅដើមខែធ្នូខាងមុខ ដែលនេះបង្ហាញពីសញ្ញាយ៉ាងវិជ្ជមានចំពោះការផ្លាស់ប្តូររវាងប្រជាជននិងប្រជាជន ការដឹកជញ្ជូនទំនិញ ផលិតផលទៅវិញទៅមកកាន់តែរីកចម្រើន ព្រមទាំងធ្វើឱ្យវិស័យផ្សេងៗមានទំនាក់ទំនងកាន់តែល្អប្រសើរថែមទៀត។

ជាមួយគ្នានោះ **សម្តេចតេជោ** ក៏បានសម្តែងនូវការសោកស្តាយចំពោះគ្រោះមហន្តរាយធម្មជាតិ ដែលបានកើតឡើងក្នុងប្រទេសវៀតណាមធ្វើឱ្យមានការខូចខាតមួយចំនួនផងដែរ។

ក្នុងឱកាសនោះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រីវៀតណាម** បានថ្លែងអំណរគុណចំពោះមនោសញ្ចេតនារបស់**សម្តេចតេជោ** ដែលបានចូលរួមសោកស្តាយចំពោះគ្រោះមហន្តរាយធម្មជាតិនៅប្រទេសវៀតណាម។ ទន្ទឹមនឹងនោះ ឯកឧត្តមក៏បាននាំនូវការផ្តាំផ្ញើសួរសុខទុក្ខពីសំណាក់ឯកឧត្តម **តូ ឡឹម** អគ្គលេខាធិការបក្សកុម្មុយនីស្ត, **ឯកឧត្តមប្រធានរដ្ឋសភា** និង**ឯកឧត្តមនាយករដ្ឋមន្ត្រីវៀតណាម** ជូនចំពោះ**សម្តេចតេជោ**ផងដែរ។

ជាចុងក្រោយ **សម្តេចតេជោ** បានជូនពរ**ឯកឧត្តមឧបនាយករដ្ឋមន្ត្រីវៀតណាម** និងគណៈប្រតិភូ ទទួលបានជោគជ័យក្នុងឱកាសបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា៕

ប្រភព៖ Telegram Channel សម្តេចតេជោ
សម្រួលខ្លឹមសារ, រូបភាព៖ នាយកដ្ឋានព័ត៌មាន



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

# សម្តេចតេជោ៖ កម្ពុជាស្វាគមន៍ចំពោះការវិលត្រឡប់របស់កាណាដា មកបើកនិវេសនដ្ឋានស្ថានទូតប្រចាំនៅកម្ពុជា

នៅវិមានព្រឹទ្ធសភា នាព្រឹកថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២៥ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា បានស្វាគមន៍និងបានចាត់ទុកវត្តមានរបស់**ឯកឧត្តមឯកអគ្គរដ្ឋទូតកាណាដា**នឹងធ្វើឱ្យទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរកាន់តែរីកចម្រើនបន្ថែមទៀត។ ទន្ទឹមនឹងនេះ **សម្តេច**ក៏បានបញ្ជាក់ថា កម្ពុជាសូមស្វាគមន៍ចំពោះការវិលត្រឡប់របស់កាណាដាមកបើកនិវេសនដ្ឋានស្ថានទូត ប្រចាំនៅព្រះរាជាណាចក្រកម្ពុជាដែលបញ្ជាក់ឱ្យឃើញយ៉ាងច្បាស់អំពីការយកចិត្តទុកដាក់និងការលើកកម្ពស់ទំនាក់ទំនងមិត្តភាពរវាងប្រទេសទាំងពីរ។



*ឯកឧត្តម Christian DesRoches និងសម្តេចតេជោ ហ៊ុន សែន*



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

ក្នុងឱកាសនោះ **ឯកឧត្តមឯកអគ្គរដ្ឋទូត** បានបង្ហាញនូវភាពរីកចម្រើននៃទំនាក់ទំនងកម្ពុជានិងកាណាដា ហើយឯកឧត្តមផ្ទាល់ក៏ជាអ្នកស្រឡាញ់ប្រទេសកម្ពុជា ដោយបានសិក្សានិងអាចនិយាយភាសាខ្មែរបានទៀតផង។ ឯកឧត្តមសង្ឃឹមថា នឹងជួយជំរុញទំនាក់ទំនងពាណិជ្ជកម្មនិងវិនិយោគរវាងប្រទេសទាំងពីរឱ្យកាន់តែរីកចម្រើន។ ទំនាក់ទំនងពាណិជ្ជកម្មរវាងប្រទេសទាំងពីរ នៅក្នុងរយៈពេលថ្មីៗនេះកំពុងមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ដែលស្របតាមការកើនឡើងនៃទំនាក់ទំនងទ្វេភាគីផ្នែកនយោបាយនិងការទូតរវាងកម្ពុជានិងកាណាដា។

**សម្តេចតេជោ** បានស្វាគមន៍ចំពោះការលើកឡើងរបស់**ឯកឧត្តមឯកអគ្គរដ្ឋទូត** ជាពិសេសទំនាក់ទំនងពាណិជ្ជកម្មកម្ពុជា និងកាណាដា មានការកើនឡើងដល់ជាង១ពាន់លានដុល្លារ ដែលជាលទ្ធផលកើតចេញពីការប្តេជ្ញាចិត្តនិងការខិតខំប្រឹងប្រែងរវាងភាគីទាំងពីរ ទោះបីជាប្រទេសទាំងពីរនៅឆ្ងាយពីគ្នាក៏ដោយ។ **សម្តេច**សង្ឃឹមថា ប្រទេសទាំងពីរនឹងរួមសហការគ្នាបន្ថែមទៀត ដើម្បីពូនជ្រំនូវទំនាក់ទំនងរវាងប្រទេសទាំងពីរ ដែលជាទំនាក់ទំនងប្រវត្តិសាស្ត្រយូរមកហើយ ដែលមកដល់ពេលនេះនៅតែរក្សាបាននូវទំនាក់ទំនងដ៏ល្អនិងជាផ្នែកនៃការរុញច្រាននៃទំនាក់ទំនងដទៃទៀត ទាំងផ្នែកពាណិជ្ជកម្មនិងវិនិយោគ ជាពិសេសផ្នែកវិនិយោគនៅកម្ពុជាបន្ថែមទៀត។

**ឯកឧត្តមឯកអគ្គរដ្ឋទូត** បានសម្តែងនូវការចាប់អារម្មណ៍ចំពោះតួអង្គរបស់**សម្តេចតេជោ** និងប្រវត្តិតស៊ូរបស់**សម្តេច**តាំងពីឯកឧត្តមនៅកាណាដាមកម្ល៉េះ។ ឯកឧត្តមបានសន្យាថា នឹងជំរុញឱ្យអ្នកវិនិយោគកាណាដាមកវិនិយោគបន្ថែមទៀតនៅកម្ពុជា ព្រមទាំងបានលើកឡើងអំពីភាពជោគជ័យរបស់ធនាគារ ABA ជាធនាគាររបស់កាណាដា ក្នុងការវិនិយោគនៅកម្ពុជា។

ជាចុងក្រោយ **សម្តេចតេជោ** បានជូនពរ**ឯកឧត្តមឯកអគ្គរដ្ឋទូត** ទទួលបាននូវភាពជោគជ័យក្នុងភារកិច្ចការងារ៕

ប្រភព៖ Telegram Channel សម្តេចតេជោ

សម្រួលខ្លឹមសារ, រូបភាព៖ នាយកដ្ឋានព័ត៌មាន

# ប្រទេសឆែក នឹងជម្រុញបន្ថែមការវិនិយោគលើវិស័យកសិកម្មនៅកម្ពុជា



*លោកជំទាវ ម៉ាកេតា ខូលហាចកូវ៉ា និងសម្តេចតេជោ ហ៊ុន សែន*



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

ក្នុងឱកាសចូលជួបសម្តែងការគួរសមជាមួយ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានព្រឹទ្ធសភា នាព្រឹកថ្ងៃអង្គារ ទី២ ខែធ្នូ ឆ្នាំ២០២៥ លោកជំទាវ **ម៉ាកេតា ខូល ហាចកូវ៉ា** (Marketa Kolc Hajkova) ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋឆែក ប្រចាំព្រះរាជាណាចក្រកម្ពុជា បានជម្រាប **សម្តេចតេជោ** ជ្រាបថា នាពេលខាងមុខ អ្នកវិនិយោគមកពីប្រទេសឆែក នឹងមកវិនិយោគលើវិស័យកសិកម្ម គឺជំណាំម្រេចនៅកម្ពុជា។

**លោកជំទាវឯកអគ្គរដ្ឋទូត** បានគូសបញ្ជាក់ថា ក្នុងអាណត្តិរបស់លោកជំទាវ នឹងធ្វើយ៉ាងណាជំរុញទំនាក់ទំនងនិងសហប្រតិបត្តិការរវាងកម្ពុជានិងឆែក ឱ្យមានភាពរីកចម្រើននិងល្អប្រសើរ ជាពិសេសលើវិស័យពាណិជ្ជកម្ម និងការវិនិយោគរវាងប្រទេសទាំងពីរ។ លោកជំទាវ នឹងប្រឹងប្រែងកៀរគរអ្នកវិនិយោគ នៅក្នុងសាធារណរដ្ឋឆែកឱ្យមកវិនិយោគនៅកម្ពុជា ដើម្បីស្វែងរកឱកាសក្នុងការវិនិយោគទៅលើវិស័យសំខាន់ៗផ្សេងទៀត។ ហើយក្នុងឱកាសខួបលើកទី៧៥ នៃទំនាក់ទំនងការទូតនៃប្រទេសទាំងពីរ លោកជំទាវ នឹងខិតខំរៀបចំព្រឹត្តិការណ៍នានា រួមទាំងដំណើរទស្សនកិច្ចផ្លូវការរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់នៃសាធារណរដ្ឋឆែក មកកាន់ព្រះរាជាណាចក្រកម្ពុជា។

នៅក្នុងជំនួបនោះ **សម្តេចតេជោ** បានស្វាគមន៍ចំពោះ**លោកជំទាវឯកអគ្គរដ្ឋទូតឆែក** និងសហការី ព្រមទាំងបានចាត់ទុកវត្តមានរបស់លោកជំទាវ ដែលត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូតថ្មីប្រចាំកម្ពុជាដ៏ឆាប់រហ័សនេះ គឺបង្ហាញយ៉ាងច្បាស់អំពីការផ្តល់តម្លៃនៃទំនាក់ទំនងនិងសហប្រតិបត្តិការដ៏ល្អរវាងសាធារណរដ្ឋឆែក និងព្រះរាជាណាចក្រកម្ពុជា។

**សម្តេចតេជោ** បានបញ្ជាក់ថា កម្ពុជានិងឆែកមានទំនាក់ទំនងជាប្រវត្តិសាស្ត្រដ៏យូរអង្វែង ហើយព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ព្រះអង្គក៏ធ្លាប់យាងទៅសិក្សានៅសាធារណរដ្ឋឆែក ដែលជានិមិត្តរូបនៃទំនាក់ទំនងដ៏ល្អប្រសើររវាងប្រទេសទាំងពីរ។

**សម្តេចតេជោ** បានលើកឡើងអំពីសក្តានុពលរវាងកម្ពុជានិងឆែក គឺនៅមានចន្លោះជាច្រើនទៀត ដែលអាចធ្វើជាមួយគ្នាឱ្យសមស្របទៅនឹងទំនាក់ទំនងការទូត និងនយោបាយរវាងប្រទេសទាំងពីរឱ្យមានភាពល្អប្រសើរ។ **សម្តេច**សង្ឃឹមថា សាធារណរដ្ឋឆែក នឹងធ្វើយ៉ាងណាចាត់ទុកកម្ពុជាជាដៃគូដ៏ល្អក្នុងការពង្រីកទំនាក់ទំនង រួមទាំងពាណិជ្ជកម្មនានា ដែលអាចធ្វើជាមួយគ្នា។ ក្រៅពីដៃគូទំនាក់ទំនងទ្វេភាគីរវាងកម្ពុជានិងឆែក ប្រទេសកម្ពុជាស្ថិតក្នុងក្របខ័ណ្ឌនៃសមាជិកអាស៊ាន រីឯសាធារណរដ្ឋឆែកស្ថិតក្នុងសហគមន៍អឺរ៉ុប ដូច្នេះសក្តានុពលទាំងទ្វេភាគីនិងពហុភាគី គឺអាចធ្វើជាមួយគ្នាច្រើន នឹងអាចផ្តល់នូវផ្លែផ្កានៅក្នុងតំបន់ទាំងពីរផង និងអាចផ្តល់ផលប្រយោជន៍ទាំងសងខាងផង។

ជាចុងក្រោយ **សម្តេចតេជោ** បានជូនពរឱ្យ**លោកជំទាវឯកអគ្គរដ្ឋទូត** ទទួលបាននូវភាពជោគជ័យក្នុងបេសកកម្មការងារ៕

ប្រភព៖ Telegram Channel សម្តេចតេជោ

សម្រួលខ្លឹមសារ, រូបភាព៖ នាយកដ្ឋានព័ត៌មាន

# កម្ពុជា-ចិន ជាមិត្តដែកថែប និងជាសហគមន៍វាសនារួមគ្រប់រដូវកាល ក្នុងយុគសម័យថ្មីដែលជាទំនាក់ទំនងដ៏ស៊ីជម្រៅ



*ឯកឧត្តមសាស្ត្រាចារ្យ Xie Chuntao និងសម្តេចតេជោ ហ៊ុន សែន*



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

កម្ពុជានិងចិន គឺជាមិត្តដែកថែបនិងជាសហគមន៍វាសនារួមគ្រប់រដូវកាល ក្នុងយុគសម័យថ្មី ហើយសង្ឃឹមថា កិច្ចសហប្រតិបត្តិការរវាងគណបក្សទាំងពីរ នឹងកាន់តែរឹងមាំនិងរីកចម្រើនបន្ថែមទៀត។ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភាកម្ពុជា បានបញ្ជាក់យ៉ាងដូច្នេះក្នុងឱកាសអនុញ្ញាតឱ្យឯកឧត្តមសាស្ត្រាចារ្យ Xie Chuntao អនុប្រធានប្រតិបត្តិសាលាបក្សនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តចិននិងជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តចិន អាណត្តិទី២០ ចូលជួបសម្តែងការគួរសម នៅវិមាន៧មករា នារសៀលថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៥ ។

**សម្តេចតេជោ** បានស្វាគមន៍យ៉ាងកក់ក្តៅនិងចាត់ទុកវត្តមានរបស់ឯកឧត្តមសាស្ត្រាចារ្យ Xie Chuntao គឺមានសារៈសំខាន់ក្នុងការពង្រឹងនិងពង្រីកទំនាក់ទំនងមិត្តភាព ប្រពៃណី និងកិច្ចសហប្រតិបត្តិការយុទ្ធសាស្ត្រកម្ពុជានិងចិនឱ្យកាន់តែជិតស្និទ្ធ។

នៅក្នុងជំនួបនោះ ឯកឧត្តមសាស្ត្រាចារ្យ Xie Chuntao បានអរគុណចំពោះ**សម្តេចតេជោ** ដែលបានអនុញ្ញាតឱ្យឯកឧត្តមនិងគណៈប្រតិភូ បានចូលជួបសម្តែងការគួរសម។ **ឯកឧត្តមសាស្ត្រាចារ្យ** បានវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនងដ៏ល្អនិងជិតស្និទ្ធរវាងកម្ពុជានិងចិន ព្រមទាំងភាពរីកចម្រើននៃទំនាក់ទំនងរវាងគណបក្សទាំងពីរ។ ឯកឧត្តមសង្ឃឹមថា ដំណើរទស្សនកិច្ចនេះ នឹងរួមចំណែកបន្ថែមទៀត ក្នុងការពង្រឹងចំណងមិត្តភាពរវាងគណបក្សទាំងពីរនិងកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌ នៃការផ្លាស់ប្តូរនូវដំណើរទស្សនកិច្ចរវាងសមាជិកគណបក្សលើការបណ្តុះបណ្តាលធនធានមនុស្សឱ្យកាន់តែមានប្រសិទ្ធភាព។

ជាការឆ្លើយតប **សម្តេចតេជោ** មានក្តីរីករាយចំពោះសហប្រតិបត្តិការដ៏ល្អប្រពៃរវាងប្រទេសទាំងពីរ ហើយសង្ឃឹមថា ប្រទេសទាំងពីរនឹងបន្តពង្រឹងកិច្ចសហប្រតិបត្តិការនិងការផ្លាស់ប្តូរទស្សនកិច្ចទៅវិញទៅមកនិងការបណ្តុះបណ្តាលពង្រឹងធនធានមនុស្សឱ្យកាន់តែរឹងមាំបន្ថែមទៀត។ ជាចុងក្រោយ **សម្តេចតេជោ** បានជូនពរ**ឯកឧត្តមសាស្ត្រាចារ្យ** និងគណៈប្រតិភូ ទទួលបានជោគជ័យក្នុងការបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា៕

ប្រភព៖ Telegram Channel សម្តេចតេជោ

រូបភាព៖ នាយកដ្ឋានព័ត៌មាន

# ឯកឧត្តម អ៊ុច បូរិទ្ធ អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការ អចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៤

នៅរសៀលថ្ងៃចន្ទ ទី១ ខែធ្នូ ឆ្នាំ២០២៥ នៅវិមានព្រឹទ្ធសភា ឯកឧត្តម **អ៊ុច បូរិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៥ ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៤ រួមមាន៖



ឯកឧត្តម អ៊ុច បូរិទ្ធ ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

១-ពិនិត្យសំណើរបស់រដ្ឋសភា សុំពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤។

២-ពិនិត្យសំណើរបស់រដ្ឋសភា សុំពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦។

៣-ពិនិត្យសំណើរបស់រដ្ឋសភា សុំពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើ៖

- ១-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធនិងការចៀសវាងពន្ធ
- ២-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋហ្វីលីពីន ស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ





ទិដ្ឋភាពក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

៣-ពិធីសារទី២ ដើម្បីធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាល នៃសាធារណរដ្ឋសិង្ហបុរី ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នានិងការបង្ការការគិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល។

៤-ផ្សេងៗ។

ក្រោយពីបានពិនិត្យ និងពិភាក្សារួចមក គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានសម្រេចៈ

-បញ្ជូនសេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤និងសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦ ទៅគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃព្រឹទ្ធសភា ដើម្បីពិនិត្យសិក្សានិងផ្តល់យោបល់។

-បញ្ជូនសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើៈ

១-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យ-ប្រជាមានិតឡាវ ស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធនិងការចៀសវាងពន្ធ

២-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋហ្វីលីពីន ស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ

៣-ពិធីសារទី២ ដើម្បីធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាល នៃសាធារណរដ្ឋសិង្ហបុរី ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នានិងការបង្ការការគិបកេងបន្លំពន្ធ ពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល ទៅគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាន នៃព្រឹទ្ធសភា ដើម្បីពិនិត្យសិក្សានិងផ្តល់យោបល់៕



*ទិដ្ឋភាពក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*

អត្ថបទ និងរូបភាពៈ នាយកដ្ឋានព័ត៌មាន

# ឯកឧត្តម អ៊ុច បូរិទ្ធ អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៥

នាព្រឹកថ្ងៃសុក្រ ទី៥ ខែធ្នូ ឆ្នាំ២០២៥ វេលាម៉ោង៨:០០នាទី ឯកឧត្តម **អ៊ុច បូរិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៥ ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៥ មានដូចខាងក្រោម៖

១-ពិនិត្យនិងសម្រេចលើសំណើរបស់គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃព្រឹទ្ធសភា (គណៈកម្មការទី២) សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី៤ ព្រឹទ្ធសភានីតិកាលទី៥។



ឯកឧត្តម អ៊ុច បូរិទ្ធ ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

២-ពិនិត្យនិងសម្រេចលើសំណើរបស់គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃព្រឹទ្ធសភា (គណៈកម្មការទី២) សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦ ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី៤ព្រឹទ្ធសភា នីតិកាលទី៥។

៣-ពិនិត្យនិងសម្រេចលើសំណើរបស់គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាន នៃព្រឹទ្ធសភា (គណៈកម្មការទី៥) សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើ៖

១.កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធនិងការចៀសវាងពន្ធ

២.កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋហ្វីលីពីន ស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ

៣.ពិធីសារទី២ ដើម្បីធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរី ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការកិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី៤ព្រឹទ្ធសភា នីតិកាលទី៥។

៤-កំណត់កាលបរិច្ឆេទ និងរបៀបវារៈបន្តសម័យប្រជុំលើកទី៤ព្រឹទ្ធសភា នីតិកាលទី៥។

៥-ផ្សេងៗ។

បន្ទាប់ពីបានពិនិត្យនិងពិភាក្សារួចមក គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានកំណត់យកថ្ងៃដដែល វេលាម៉ោង៩:០០នាទី បន្តសម័យប្រជុំលើកទី៤ព្រឹទ្ធសភា នីតិកាលទី៥ ដើម្បីពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន៣ខាងលើនេះ៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន



ទិដ្ឋភាពក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

# ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញដឹកនាំការបន្តសម័យប្រជុំ លើកទី៤ ដើម្បីពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន៣




*ឯកឧត្តម អ៊ុច បូររិទ្ធ ប្រធានស្តីទីព្រឹទ្ធសភា និងឯកឧត្តមបណ្ឌិត ជន់ វឌ្ឍនា អនុប្រធានទី២ព្រឹទ្ធសភា*

នាព្រឹកថ្ងៃសុក្រ ទី៥ ខែធ្នូ ឆ្នាំ២០២៥ នៅវេលាម៉ោង៩:០០នាទី ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានបន្តសម័យប្រជុំលើកទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **អ៊ុច បូររិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភា ដោយមានវត្តមានសមាជិកព្រឹទ្ធសភាចូលរួមចំនួន៥៨រូប។



*ឯកឧត្តម អ៊ុច បូររិទ្ធ មានប្រសាសន៍ក្នុងសម័យប្រជុំព្រឹទ្ធសភា*

អង្គប្រជុំបានដំណើរការដោយមានរបៀបវារៈចំនួន៣ ដូចខាងក្រោម៖

**របៀបវារៈទី១៖ ពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤។**

សេចក្តីព្រាងច្បាប់នេះ បង្ហាញនូវប្រតិបត្តិការថវិកាដែលបានអនុវត្តយ៉ាងសកម្មនិងពេញលេញ ប្រកបដោយភាពស្វាហាប់របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ដឹកនាំដោយសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** ដែលបានដឹកនាំប្រទេសចាកចេញពីផលវិបាកបន្សល់ពីវិបត្តិជំងឺកូវីដ-១៩ អនុវត្តពេញទំហឹងនូវកម្មវិធីអាទិភាពទាំង៦និងវិធានការគន្លឹះទាំង៥ នៃយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ជាពិសេស ការកសាងនូវប្រព័ន្ធគាំពារសង្គម ដែលជាអាទិភាពដ៏លេចធ្លោបំផុតនៅក្នុងចំណោមកម្មវិធីអាទិភាពទាំង៦ ដែលទទួលបានការអបអរពីប្រជាពលរដ្ឋទូទាំងប្រទេសជាពិសេសការពង្រីកការគ្របដណ្តប់ការផ្តល់ប័ណ្ណ ប.ស.សនិងសេវាមូលនិធិគាំពារសង្គមនិងវិស័យអាទិភាពដទៃទៀត រួមមាន សុខាភិបាល អប់រំ និងសេដ្ឋកិច្ច ដែលបានប្រព្រឹត្តទៅព្រមៗគ្នានៅឆ្នាំ២០២៤ ដើម្បីជំរុញសន្ទុះកំណើនសេដ្ឋកិច្ចកម្ពុជាឆ្ពោះទៅឆ្នាំ២០៣០ និង២០៥០។

សេចក្តីព្រាងច្បាប់នេះ រៀបចំឡើងមាន៥ជំពូកនិង២៩មាត្រា ត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា អនុម័ត

យល់ព្រមលើកដំបូងចំនួន១១០សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូល កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៥ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៧។


ឯកឧត្តម យស ផានីត្តា ឡើងអានរបាយការណ៍


ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឡើងការពារសេចក្តីព្រាងច្បាប់

សេចក្តីព្រាងច្បាប់នេះ ត្រូវបានឯកឧត្តម **យស ផានីត្តា** ប្រធានគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃព្រឹទ្ធសភា អញ្ជើញឡើងរាយការណ៍អំពីលទ្ធផលនៃការពិនិត្យនិងសិក្សាសេចក្តីព្រាងច្បាប់ និងមានសមាជិកព្រឹទ្ធសភាចំនួន១រូប ឡើងមានយោបល់ ហើយអង្គប្រជុំព្រឹទ្ធសភា បានពិនិត្យហើយឱ្យយោបល់ឯកភាពទាំងស្រុងលើសេចក្តីព្រាងច្បាប់ ដោយឥតកែប្រែចំនួន៥៨សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

**របៀបវារៈទី២៖ ពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦។**

សេចក្តីព្រាងច្បាប់នេះ រៀបចំឡើងដើម្បីកំណត់អាទិភាពលើកិច្ចការការពារបូរណភាពទឹកដី និងការប្តេជ្ញាបន្តសកម្មភាពនានា ដែលមានចែងនៅក្នុងកម្មវិធីអាទិភាពនៃយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ ដឹកនាំដោយ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាដោយមានការគិតគូរយ៉ាងល្អិតល្អន់អំពីក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ២០២៦-២០២៨ សម្រាប់បម្រើឱ្យគោលបំណងសំខាន់ចំនួន៣ រួមមាន៖ ១-ការគាំទ្រការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ២-ការពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូល និងការវិភាជន៍ថវិកា និង៣-ការចូលរួមជានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងចីរភាពហិរញ្ញវត្ថុសាធារណៈ។ ទន្ទឹមនឹងនេះ សេចក្តីព្រាងច្បាប់នេះ រៀបចំឡើងប្រកបដោយការប្រុងប្រយ័ត្ន ពេញលេញ និងការទទួលខុសត្រូវខ្ពស់ដោយឈរលើអភិក្រម «សង្ឃឹមសម្រាប់ស្ថានភាពប្រសើរ តែត្រៀមខ្លួនសម្រាប់ស្ថានភាពអាក្រក់»។

សេចក្តីព្រាងច្បាប់នេះ រៀបចំឡើងមាន៦ជំពូកនិង១៥មាត្រា ត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា អនុម័តយល់ព្រមលើកដំបូងចំនួន១០៨សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូល កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៥ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៧។

សេចក្តីព្រាងច្បាប់នេះ ក៏ត្រូវបានឯកឧត្តម **យស ផានីត្តា** ប្រធានគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃព្រឹទ្ធសភា អញ្ជើញឡើងរាយការណ៍អំពីលទ្ធផលនៃការពិនិត្យសិក្សាសេចក្តីព្រាងច្បាប់និងមានសមាជិកព្រឹទ្ធសភាចំនួន៤រូប ឡើងមានយោបល់ ហើយអង្គប្រជុំព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់ឯកភាពទាំងស្រុងលើសេចក្តីព្រាងច្បាប់ទាំងមូលដោយឥតកែប្រែចំនួន៥៧សំឡេងនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

របៀបវារៈទី៣៖ពិនិត្យហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើ៖

១-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ស្ដីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធនិងការចៀសវាងពន្ធ

២-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋហ្វីលីពីន ស្ដីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ

៣-ពិធីសារទី២ ដើម្បីធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរី ស្ដីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការកិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល។

កិច្ចព្រមព្រៀងស្ដីពីការចៀសវាងការយកពន្ធត្រួតគ្នា កម្ពុជា-ឡាវ និងកម្ពុជា-ហ្វីលីពីន គឺជាការបែងចែកសិទ្ធិក្នុងការយកពន្ធរវាងគូភាគីនៃប្រទេសជាហត្ថលេខី ដែលម្ខាងអាចកម្រិតផ្នែកខ្លះនៃការអនុវត្តច្បាប់និងបទប្បញ្ញត្តិក្នុងស្រុកស្ដីពីពន្ធដារ ហើយនៅក្នុងដំណាក់កាលនៃការអនុវត្តដំបូងអាចមានផលប៉ះពាល់ផ្ទាល់ដល់ចំណូលពន្ធរបស់ប្រទេសប្រភព ដោយសារការកាត់បន្ថយអត្រាពន្ធកាត់ទុក ដែលត្រូវអនុវត្តចំពោះអ្នកជាប់ពន្ធអនិវាសនជន និងការបែងចែកសិទ្ធិយកពន្ធលើប្រភេទប្រាក់ចំណូលមួយចំនួនឱ្យទៅប្រទេសនិវាសនដ្ឋាន។

ចំពោះពិធីសារទី២ ដើម្បីធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងស្ដីពី ការចៀសវាងការយកពន្ធត្រួតគ្នារវាងកម្ពុជានិងសិង្ហបុរី មានគោលបំណងកែសម្រួលនិងធ្វើឱ្យប្រសើរឡើងនូវកិច្ចព្រមព្រៀងដែលមានស្រាប់ អាចឆ្លើយតបទៅនឹងការវិវត្តថ្មីៗ នៅក្នុងបរិបទពន្ធដារអន្តរជាតិ ដូចជាបានកែសម្រួលចំណងជើងនិងបុព្វកថារបស់កិច្ចព្រមព្រៀង និងបន្ថែមមាត្រាស្ដីពីសិទ្ធិទទួលផលប្រយោជន៍។ ការធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងតាមរយៈពិធីសារទី២នេះ ក៏ដើម្បីឱ្យមានសង្គតិភាពជាមួយស្តង់ដាអប្បបរមា នៃក្របខ័ណ្ឌបរិយាបន្នរបស់អង្គការសហប្រតិបត្តិការនិងអភិវឌ្ឍន៍សេដ្ឋកិច្ច និងប្រទេសដែលមានសេដ្ឋកិច្ចធំ២០ (G20) សម្រាប់ប្រឈមនឹងការបន្ថយមូលដ្ឋានគិតពន្ធនិងការបង្វែរប្រាក់ចំណេញផងដែរ។

កិច្ចព្រមព្រៀងទាំងពីរ និងពិធីសារទី២ នឹងផ្តល់នូវអត្ថប្រយោជន៍ដល់ព្រះរាជាណាចក្រកម្ពុជា ដូចជា៖ ១-ការទាក់ទាញនិងជំរុញវិនិយោគនិងពាណិជ្ជកម្មអន្តរជាតិ ដោយសារការផ្តល់នូវភាពច្បាស់លាស់ តម្លាភាពនិងគ្មានការរើស-





*ទិដ្ឋភាពក្នុងសម័យប្រជុំលើកទី៤ព្រឹទ្ធសភា នីតិកាលទី៥*

អើងក្នុងវិស័យពន្ធដារ ២-កំណើនមូលដ្ឋានពន្ធ ៣-រំហូរមូលធន ដោយសារភាពទាក់ទាញនៃអត្រាពន្ធកាត់ទុកលើភាគលាភនិងការប្រាក់ ៤-ការផ្ទេរបច្ចេកវិទ្យានិងជំនាញពីបរទេស តាមរយៈបទប្បញ្ញត្តិ ស្តីពីសួយសារនិងសេវាបច្ចេកទេស ៥-ការការពារនិវាសនជនកម្ពុជាដែលជាវិនិយោគិននៅបរទេស ៦-ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងវិស័យពន្ធដារ ជាពិសេសការទប់ស្កាត់និងការបង្ក្រាបការគេចវេះពន្ធតាមរយៈការផ្លាស់ប្តូរព័ត៌មានរបស់អ្នកជាប់ពន្ធ។

សេចក្តីព្រាងច្បាប់នេះ រៀបចំឡើងមាន២មាត្រា ត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា អនុម័តយល់ព្រមលើកដំបូងចំនួន១០៨សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូល កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៥ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៧។



*ឯកឧត្តមបណ្ឌិត ថែម វីឡា ឡើងអានរបាយការណ៍*


*ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឡើងការពារសេចក្តីព្រាងច្បាប់*

សេចក្តីព្រាងច្បាប់នេះ ត្រូវបានឯកឧត្តមបណ្ឌិត **ថែម វីឡា** ប្រធានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាន នៃព្រឹទ្ធសភា អញ្ជើញឡើងរាយការណ៍អំពីលទ្ធផលនៃការពិនិត្យសិក្សាសេចក្តីព្រាងច្បាប់ និងមានសមាជិកព្រឹទ្ធសភាចំនួន២រូប ឡើងមានយោបល់ ហើយអង្គប្រជុំព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់ឯកភាពទាំងស្រុងលើសេចក្តីព្រាងច្បាប់ទាំងមូលដោយឥតកែប្រែចំនួន៥៧សំឡេងនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

សូមជម្រាបថា សេចក្តីព្រាងច្បាប់ទាំង៣ខាងលើ ត្រូវបានឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អញ្ជើញឆ្លើយបំភ្លឺជូនអង្គប្រជុំព្រឹទ្ធសភា៕




*សមាជិក សមាជិកាព្រឹទ្ធសភាលើកដៃអនុម័តសេចក្តីព្រាងច្បាប់*

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន

# ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា អញ្ជើញប្រគល់ផ្ទះ និងនាំយកអំណោយចែកជូនគ្រួសារក្រីក្រ នៅស្រុកកងមាស និងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម




*ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញសំណេះសំណាលជាមួយប្រជាពលរដ្ឋ នៅស្រុកកងមាស*

នាព្រឹកថ្ងៃសុក្រ ទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភានិងជាប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ អមដំណើរដោយឯកឧត្តម លោកជំទាវ សមាជិក សមាជិកាព្រឹទ្ធសភា ក្រុមការងារភូមិភាគ២ ទីប្រឹក្សា និងមន្ត្រីខុទ្ទកាល័យ បានអញ្ជើញប្រគល់ផ្ទះចំនួន២ខ្នង និងសម្ភារៈប្រើប្រាស់ចាំបាច់ក្នុងផ្ទះជូនដល់២គ្រួសារ និងនាំយកអំណោយជាគ្រឿងឧបភោគ បរិភោគ ព្រមទាំងសម្ភារៈប្រើប្រាស់ ដែលជាអំណោយដ៏ថ្លៃថ្លារបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ព្រមទាំងសប្បុរសជននានា ចែកជូនដល់ប្រជាពលរដ្ឋក្រីក្រចំនួន៦០គ្រួសារផ្សេងទៀត រស់នៅក្នុងស្រុកកងមាស និងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ដើម្បីឱ្យប្រជាពលរដ្ឋតាមមូលដ្ឋានទទួលបានលំនៅឋានសមរម្យនិងការដោះស្រាយតម្រូវការក្នុងជីវភាពប្រចាំថ្ងៃ។

ក្នុងកិច្ចសំណេះសំណាល, **ឯកឧត្តមអនុប្រធានទី១** បាននាំការផ្តាំផ្ញើសួរសុខទុក្ខនិងក្តីនឹករលឹករបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ជូនចំពោះបងប្អូនប្រជាពលរដ្ឋ និងបានគូសបញ្ជាក់ពីការយកចិត្តទុកដាក់ខ្ពស់របស់**សម្តេច**ទាំងទ្វេនៅគ្រប់កាលៈទេសៈ ចំពោះសុខទុក្ខ និងជីវភាពរស់នៅរបស់បងប្អូនប្រជាពលរដ្ឋមូលដ្ឋានគ្រប់ស្រទាប់វណ្ណៈ ដោយមិនប្រកាន់ជំនឿសាសនា ពណ៌សម្បុរ ឬនិន្នាការនយោបាយសោះឡើយ។ ដោយប្រតិបត្តិតាមអនុសាសន៍ដ៏ឧត្តុង្គឧត្តមថ្លៃថ្លា ប្រកបដោយគតិបណ្ឌិត និងទស្សនវិស័យវែងឆ្ងាយរបស់**សម្តេចប្រធាន** សមាជិក សមាជិកាព្រឹទ្ធសភានីតិកាលទី៥ បានខិតខំអនុវត្តការងារចុះជាប់ជាប្រចាំជាមួយអង្គបោះឆ្នោតជាមួយប្រជាពលរដ្ឋតាមមូលដ្ឋាន ដែលជាអាទិភាពមួយក្នុងចំនួនអាទិភាពទាំងពីរ សំដៅរួមចំណែកអនុវត្តឱ្យបានជោគជ័យ «យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១» ដើម្បីកំណើនការងារសមធម៌ ប្រសិទ្ធភាព និងចីរភាព។ នៅក្នុងស្មារតីនេះ តាមរយៈព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ដៃគូអភិវឌ្ឍន៍បរទេស អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិមួយចំនួន ដែលមានជាអាទិ៍ អង្គការចែករំលែកសង្គ្រោះជីវិតសកល(Global Life Sharing) អង្គការគ្រូពេទ្យស្ម័គ្រចិត្តប៊ីឃោដៃរម៉ាបានផ្តល់ជាអំណោយឱសថ សាងសង់លំនៅឋានជូនប្រជាជនក្រីក្រ និងសេវាព្យាបាលជំងឺដោយឥតគិត




*ឯកឧត្តម អ៊ុច បូរិទ្ធ អញ្ជើញសំណេះសំណាលជាមួយប្រជាពលរដ្ឋ នៅស្រុកស្ទឹងត្រង់*

កម្រៃ ជូនដល់ប្រជាពលរដ្ឋជាបន្តបន្ទាប់ រួមចំណែកដ៏សំខាន់ក្នុងការលើកកម្ពស់សុខុមាលភាពប្រជាជននិងការអភិវឌ្ឍប្រទេសជាតិ។ ជាមួយគ្នានោះ **ឯកឧត្តមអនុប្រធានទី១** ក៏បានក្រើនរំឭកដល់ក្មួយៗសិស្ស និស្សិត ខិតខំរៀនសូត្រ ដើម្បីប្រែក្លាយខ្លួនជាទំពាំងស្នងឫស្សី បន្តវេនការពារអធិបតេយ្យ ឯករាជ្យភាព និងបូរណភាពដែនដីកម្ពុជា។

**ឯកឧត្តមអនុប្រធានទី១** បានជម្រាបជូនប្រជាពលរដ្ឋអំពីស្ថានភាព ដើមចម និងមហិច្ឆតាគឃ្លើនឈ្លានពានរបស់ថៃមកលើបូរណភាពទឹកដីកម្ពុជា ដោយបានគូសបញ្ជាក់ពីមោទនភាពជាតិខ្ពស់បំផុតចំពោះសាមគ្គីភាព ឯកភាពជាតិជាធ្លុងមួយជុំវិញរាជរដ្ឋាភិបាល ដែលមាន **សម្តេចធិបតី** ជាមគ្គុទេសក៏ដ៏ឈ្លាសវៃ ក្នុងការតស៊ូប្រយុទ្ធការពារបូរណភាពដែនដីមាតុភូមិកម្ពុជា ប្រឆាំងនឹងពួកឈ្លានពានថៃ។

ជាកិច្ចឆ្លើយតប បងប្អូនប្រជាពលរដ្ឋទាំងអស់បានសម្តែងនូវអំណរគុណនិងសូមប្រសិទ្ធពរជ័យជូន**សម្តេចតេជោ** ប្រធានព្រឹទ្ធសភា **សម្តេចធិបតី** សូមប្រកបតែសុខភាពល្អ និងប្តេជ្ញារួមសាមគ្គីជាធ្លុងមួយ ជាមួយរាជរដ្ឋាភិបាលការពារអធិបតេយ្យ ឯករាជ្យភាព បូរណភាពដែនដី និងអភិវឌ្ឍប្រទេសជាតិ៕



*ថតរូបអនុស្សាវរីយ៍ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ជាមួយក្រុមការងារ នៅស្រុកស្ទឹងត្រង់*

ខ្លឹមសារ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា

រូបភាព៖ នាយកដ្ឋានព័ត៌មាន

# ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា អញ្ជើញចុះសួរសុខទុក្ខ និងនាំយកអំណោយជូនកងទ័ពសមរភូមិមុខ និងគ្រួសារយុទ្ធជន នៅខេត្តឧត្តរមានជ័យ និងខេត្តបាត់ដំបង





*ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញចុះសួរសុខទុក្ខ និងនាំយកអំណោយជូនកងទ័ពសមរភូមិមុខ និងគ្រួសារយុទ្ធជន នៅខេត្តឧត្តរមានជ័យ*

នាថ្ងៃសៅរ៍ ទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា អមដំណើរដោយឯកឧត្តម លោកជំទាវ សមាជិក សមាជិកាព្រឹទ្ធសភា ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទីប្រឹក្សា និងសមាជិកខុទ្ទកាល័យ បានអញ្ជើញចុះសួរសុខទុក្ខនិងនាំយកអំណោយជាគ្រឿងឧបភោគ បរិភោគ សម្ភារៈប្រើប្រាស់ចាំបាច់ផ្សេងៗ និងថវិកា ជូនវីរយុទ្ធជនការពារប្រាសាទតាមាន់ធំ ប្រាសាទតាក្របី និងគ្រួសារយុទ្ធជនចំនួន៣០០គ្រួសារ និងសម្ភារៈសិក្សាជូនដល់សិស្សានុសិស្ស នៃសាលាបឋមសិក្សាតាមន្តសែនជ័យ ដែលស្ថិតនៅឃុំគោកមន ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ។

បន្ទាប់មក នារសៀលថ្ងៃដដែល **ឯកឧត្តមអនុប្រធានទី១** បានអញ្ជើញដឹកនាំគណៈប្រតិភូចុះជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយកអំណោយជាគ្រឿងឧបភោគ បរិភោគ សម្ភារៈប្រើប្រាស់ផ្សេងៗ និងថវិកាប្រគល់ជូនយោធភូមិភាគទី៥និងគ្រួសារយុទ្ធជនចំនួន៤០០គ្រួសារ ក្នុងខេត្តបាត់ដំបង។

ក្នុងកិច្ចសំណេះសំណាលក្នុងកម្មវិធីទាំងពីរខាងលើ **ឯកឧត្តមអនុប្រធានទី១** បាននាំការផ្តាំផ្ញើសុខទុក្ខ និងក្តីនឹករលឹករបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភានិង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ដែលលោកទាំងពីរតែងតែយកចិត្តទុកដាក់ខ្ពស់ចំពោះសុខទុក្ខរបស់វីរយុទ្ធជន ដែលបាននិងកំពុងឈរជើងយ៉ាងរឹងមាំ តស៊ូក្រាញ



*ឯកឧត្តម អ៊ុច បូររិទ្ធ នាំយកសម្ភារៈសិក្សាជូនដល់សិស្សានុសិស្ស នៃសាលាបឋមសិក្សាតាមន្តសែនជ័យ*





*ឯកឧត្តម អ៊ុច បូរិទ្ធ អញ្ជើញជួបសំណេះសំណាល និងនាំយកអំណោយជូនកងទ័ពសមរភូមិមុខ និងគ្រួសារយុទ្ធជន នៅខេត្តបាត់ដំបង*

ននៀលការពារទឹកដីមាតុភូមិកម្ពុជា ព្រមទាំងក្រុមគ្រួសារវីរយុទ្ធជន បានរួមចំណែកតស៊ូប្តូរផ្តាច់លះបង់សេចក្តីសុខគ្រួសារជាទីស្រឡាញ់ ដើម្បីប្រទេសជាតិ។

ជាមួយគ្នានោះ **ឯកឧត្តមអនុប្រធានទី១** បានសម្តែងនូវគារវកិច្ចដ៏ជ្រាលជ្រៅ ចំពោះវីរភាពអង់អាចក្លាហានមោះមុតដ៏គួរឱ្យកោតស្ញប់ស្ញែងរបស់វីរយុទ្ធជន ដើម្បីបុព្វហេតុការពារជាតិមាតុភូមិកម្ពុជា ព្រមទាំងបានបួងសួងដល់គុណបុណ្យព្រះរតនៈត្រ័យ គុណកែវទាំងបី សូមតាមអភិបាលប្រោះព្រំ ឃុំគ្រងថែរក្សា និងប្រសិទ្ធពរជ័យជូនវីរយុទ្ធជនដ៏អង់អាចក្លាហាននៅតាមព្រំដែន សូមជួបតែសុខសុវត្ថិភាពនិងទទួលបានជ័យជម្នះលើសមរភូមិ កម្ចាត់បច្ចាមិត្តឈ្លានពានឱ្យវិនាសអន្តរាយ។



*ឯកឧត្តម អ៊ុច បូរិទ្ធ នាំយកអំណោយជូនកងទ័ពសមរភូមិមុខ និងគ្រួសារយុទ្ធជន នៅខេត្តបាត់ដំបង*

ជាមួយនឹងការសម្តែងនូវមនោសញ្ចេតនាជាភាតរៈរួមសុខរួមទុក្ខជាមួយបងប្អូនយុទ្ធជន និងប្រជាពលរដ្ឋ **ឯកឧត្តមអនុប្រធានទី១** បានបង្ហាញនូវមោទនភាពជាតិខ្ពស់ចំពោះទឹកចិត្តស្នេហាជាតិ សាមគ្គីឯកភាពជាតិជាធ្លុងមួយនៅគ្រប់ស្រទាប់សង្គមជាតិ គាំទ្រទាំងកម្លាំងកាយចិត្ត និងសម្ភារៈជួយដល់សមរភូមិមុខ ក្នុងការការពារទឹកដីមាតុភូមិកម្ពុជា វាយបំបាក់ឱ្យបរាជ័យរាល់ការប៉ុនប៉ងរំលោភបំពាននិងមហិច្ឆតាប្លន់ទឹកដីរបស់ពួកចោរឈ្លានពាន។

**ឯកឧត្តមអនុប្រធានទី១** ក៏បានអំពាវនាវឱ្យបងប្អូនប្រជាពលរដ្ឋទាំងអស់សូមមានជំនឿជឿជាក់លើការដឹកនាំប្រកបដោយគតិបណ្ឌិតនិងវៃឆ្លាតរបស់**សម្តេចតេជោ** ប្រធានព្រឹទ្ធសភា និងសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី ក្នុងការចាត់វិធានការនានា ដើម្បីការពារបូរណភាពដែនដី និងដោះស្រាយវិវាទព្រំប្រទល់ជាមួយប្រទេសថៃដោយសន្តិវិធី និងផ្អែកលើច្បាប់អន្តរជាតិ ធម្មនុញ្ញអង្គការសហប្រជាជាតិ និងធម្មនុញ្ញអាស៊ាន សំដៅធានាបាននូវសន្តិភាពនិងការអភិវឌ្ឍប្រកបដោយចីរភាពជូនជាតិមាតុភូមិ៕

ខ្លឹមសារ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា

រូបភាព៖ នាយកដ្ឋានព័ត៌មាន

# ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញចុះសួរសុខទុក្ខវីរយុទ្ធជនរងរបួសក្នុងពេលប្រយុទ្ធ ជាមួយកងទ័ពឈ្លានពានថៃ ដែលកំពុងសម្រាកព្យាបាល នៅតាមមន្ទីរពេទ្យជាតិចំនួន៥ ក្នុងរាជធានីភ្នំពេញ





*ឯកឧត្តម អ៊ុច បូររិទ្ធ សួរសុខទុក្ខវីរយុទ្ធជនរងរបួសនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត*

នាព្រឹកថ្ងៃសុក្រ ទី១៩ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា អមដំណើរដោយ ឯកឧត្តម **គី តិច** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមមេធាវីរាជរដ្ឋាភិបាលនិងជាប្រធានក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោសែន ព្រមទាំងសមាជិកព្រឹទ្ធសភា បានអញ្ជើញចុះសួរសុខទុក្ខវីរយុទ្ធជន ដែលកំពុងសម្រាកព្យាបាលរបួសនៅតាមមន្ទីរពេទ្យជាតិ ក្នុងរាជធានីភ្នំពេញ រួមមាន៖ មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត មន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិនព្រះកុសុមៈ មន្ទីរពេទ្យកាល់ម៉ែត មន្ទីរពេទ្យព្រះកេតុមាលា និងមន្ទីរពេទ្យព្រះអង្គឌួង។





*ឯកឧត្តម អ៊ុច បូររិទ្ធ សួរសុខទុក្ខវីរយុទ្ធជនរងរបួស នៅមន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិនព្រះកុសុមៈ*

នៅក្នុងឱកាសនោះ **ឯកឧត្តមអនុប្រធានទី១** បានពាំនាំនូវការផ្តាំផ្ញើការសួរសុខទុក្ខ និងពរសព្ទសាធុការ ពីសំណាក់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី និងលោកជំទាវបណ្ឌិត ជូនដល់បងប្អូនវីរយុទ្ធជនរបស់យើងទាំងអស់ ដែលកំពុងសម្រាកព្យាបាលរបួសនៅមន្ទីរពេទ្យ

ទាំង៥ខាងលើ សូមឱ្យបានឆាប់ជាសះស្បើយ មានសុខភាពល្អឡើងវិញ និងទទួលបានជ័យជម្នះថ្មីៗថែមទៀត នៅក្នុងការបំពេញភារកិច្ចដ៏ឧត្តុង្គឧត្តម ដើម្បីបុព្វហេតុការពារជាតិមាតុភូមិនិងប្រជាជន។ ជាមួយគ្នានោះ **ឯកឧត្តមអនុប្រធានទី១** បានសម្តែងនូវការដឹងគុណនិងគារវកិច្ចដ៏ជ្រាលជ្រៅបំផុត ចំពោះវីរភាពអង់អាចក្លាហានមោះមុតដ៏គួរឱ្យកោតស្ញប់ស្ញែងរបស់វីរយុទ្ធជន ដើម្បីបុព្វហេតុការពារជាតិមាតុភូមិកម្ពុជា និងបានប្រសិទ្ធពរជ័យជូនវីរយុទ្ធជនដ៏អង់អាចក្លាហាននៅតាមព្រំដែន បានជួបតែសុខសុវត្ថិភាព និងទទួលបានជ័យជម្នះលើសមរភូមិ កម្ចាត់បច្ចាមិត្តឈ្លានពានឱ្យវិនាសអន្តរាយ។



*ឯកឧត្តម អ៊ុច បូរិទ្ធ សួរសុខទុក្ខវីរយុទ្ធជនរងរបួស នៅមន្ទីរពេទ្យកាល់ម៉ែត*





*ឯកឧត្តម អ៊ុច បូរិទ្ធ សួរសុខទុក្ខវីរយុទ្ធជនរងរបួសនៅមន្ទីរពេទ្យព្រះកេតុមាលា*

នៅក្នុងឱកាសនោះដែរ **ឯកឧត្តមអនុប្រធានទី១** ក៏បាននាំយកនូវអំណោយជាសម្ភារៈនិងថវិកាមួយចំនួន ជូនដល់វីរយុទ្ធជន និងក្រុមគ្រួសារ ដែលជាសក្ខីភាពបង្ហាញពីទឹកចិត្តគោរព ស្រឡាញ់រាប់អានជាភាតរៈ សាមគ្គីភាព រួមសុខរួមទុក្ខ ឯកភាពជាតិជាធ្លុងមួយ ជុំវិញ**សម្តេចតេជោ ប្រធានព្រឹទ្ធសភា** និងរាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយថាមពលនិងបញ្ញាញាណរបស់ សម្តេចធិបតី **ហ៊ុន ម៉ាណែត** ក្នុងការការពារឯករាជ្យ អធិបតេយ្យ និងបូរណភាពដែនដីកម្ពុជា៕

ខ្លឹមសារ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា
រូបភាព៖ នាយកដ្ឋានព័ត៌មាន



*ឯកឧត្តម អ៊ុច បូរិទ្ធ សួរសុខទុក្ខវីរយុទ្ធជនរងរបួស នៅមន្ទីរពេទ្យព្រះអង្គឌួង*

# គោលនយោបាយអន្តរជាតិរបស់កម្ពុជា គឺកសាងមិត្ត មិនបង្កើតសត្រូវ ឈរលើគោលការណ៍ច្បាប់ និងភាពត្រឹមត្រូវ




*ឯកឧត្តម UENO Atsushi ជួបពិភាក្សាការងារជាមួយឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា អនុប្រធានទី២ព្រឹទ្ធសភា*

នៅរសៀលថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ ២០២៥ នៅសាលពិសេស៣ វិមានព្រឹទ្ធសភា ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ នៃព្រឹទ្ធសភា អមដោយឯកឧត្តមបណ្ឌិត **ចែម វីឌ្យា** ប្រធានគណៈកម្មការទី៥ ព្រឹទ្ធសភា និងថ្នាក់ដឹកនាំខុទ្ទកាល័យអនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញទទួលជួបពិភាក្សាការងារជាមួយ ឯកឧត្តម UENO Atsushi ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា រួមជាមួយលោកសាស្ត្រាចារ្យ Hosoya Yuichi អ្នកជំនាញនយោបាយអន្តរជាតិដ៏ល្បី មកពីសាកលវិទ្យាល័យ Keio និងសហការី។

នៅក្នុងជំនួបនោះ លោកសាស្ត្រាចារ្យ Hosoya បានជម្រាប**ឯកឧត្តមបណ្ឌិត** អំពីគោលនយោបាយអន្តរជាតិរបស់ជប៉ុន ដែលកំពុងអនុវត្តដោយនាយករដ្ឋមន្ត្រីថ្មី លោកជំទាវ Sanae Takaichi ជាពិសេសតួនាទីរបស់ជប៉ុនក្នុងក្របខ័ណ្ឌសន្តិសុខ និងសក្តានុភាពតំបន់នៅអាស៊ីប៉ូស៊ីហ្វិក អាស៊ាន និងទ្វីបអាហ្វ្រិក។ **លោកសាស្ត្រាចារ្យ** បានគូសបញ្ជាក់ថា កម្ពុជាតែងតែជាមិត្តល្អ និងមិត្តយូរអង្វែងរបស់ជប៉ុន ជាពិសេសកម្ពុជា គឺជាប្រទេសដំបូងបំផុត ដែលប្រកាសគាំទ្រយុទ្ធសាស្ត្រឥណ្ឌូប៉ាស៊ីហ្វិកសេរី និងបើកចំហរបស់ជប៉ុន។ លោកសង្កេតឃើញថា គោលនយោបាយអន្តរជាតិកម្ពុជា តែងតែឈរជាមួយគោលការណ៍ត្រឹមត្រូវនិងយុត្តិធម៌។

នៅក្នុងឱកាសនោះ **ឯកឧត្តមបណ្ឌិត** អនុប្រធានទី២ព្រឹទ្ធសភា បានមានប្រសាសន៍ថា គោលនយោបាយអន្តរជាតិរបស់កម្ពុជា គឺកសាងមិត្ត មិនបង្កើតសត្រូវ និងឈរលើគោលការណ៍ច្បាប់ និងភាពត្រឹមត្រូវ។ **ឯកឧត្តមបណ្ឌិត** បានបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់កម្ពុជាចំពោះដំណោះស្រាយការទូតដោយសន្តិវិធីទាក់ទងនឹងជម្លោះព្រំដែនជាមួយប្រទេសថៃ ដោយសង្កត់ធ្ងន់ពីភាពចាំបាច់នៃការគោរពច្បាប់អន្តរជាតិ ជាពិសេស គឺសេចក្តីប្រកាសរួមស្តីពីសន្តិភាពកម្ពុជា-ថៃ ដែលបានចុះហត្ថលេខា កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥។

ក្នុងកិច្ចពិភាក្សានោះ **ឯកឧត្តមបណ្ឌិត** និង**ឯកឧត្តមឯកអគ្គរាជទូតជប៉ុន** បានលើកឡើងពីសារៈសំខាន់នៃកិច្ចសហការ ដើម្បីពង្រឹងទំនាក់ទំនងកម្ពុជា-ជប៉ុនឱ្យកាន់តែរីកចម្រើនបន្ថែមទៀត ដោយផ្តោតលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ការវិនិយោគពីជប៉ុន ការបង្កើតរោងចក្រកែច្នៃ និងឥណទានសម្បទានជាដើម។

**ឯកឧត្តមបណ្ឌិត** ក៏បានលើកឡើង អំពីការស្រាវជ្រាវរួមគ្នារវាងសាកលវិទ្យាល័យ Keio និងអ្នកស្រាវជ្រាវកម្ពុជា លើវិស័យទំនាក់ទំនងអន្តរជាតិបន្ថែមទៀតផងដែរ៕

ខ្លឹមសារ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា

រូបភាព៖ នាយកដ្ឋានព័ត៌មាន

# ឯកឧត្តមបណ្ឌិត ឆន់ ខឡ្សនា លើកទឹកចិត្តមូលនិធិចិនដើម្បីសន្តិភាពនិងការអភិវឌ្ឍកសាងភូមិគំរូបន្ថែមទៀត នៅតាមភូមិភាគទាំង៨ ព្រឹទ្ធសភា ដោយផ្តោតលើការអប់រំកុមារ និងសុខភាព




*លោកស្រី វ៉ង យ៉ាហួយ ជួបពិភាក្សាការងារជាមួយឯកឧត្តមបណ្ឌិត ឆន់ ខ្សេនា អនុប្រធានទី២ព្រឹទ្ធសភា*

ឯកឧត្តមបណ្ឌិត **ឆន់ ខឡ្សនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញទទួលជួបជាមួយ លោកស្រី **វ៉ង យ៉ាហួយ** ប្រធានមូលនិធិចិនដើម្បីសន្តិភាពនិងការអភិវឌ្ឍនិងសហការី នៅវិមានព្រឹទ្ធសភា នារសៀលថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៥ ដើម្បីពិភាក្សាអំពីការលើកកម្ពស់គុណភាពជីវិតប្រជាជន តាមរយៈការផ្តល់មូលនិធិជួយវិស័យកសិកម្ម កសិ-ឧស្សាហកម្ម ការអប់រំ សុខាភិបាល និងទេសចរណ៍។

នៅក្នុងជំនួបនោះ **លោកស្រីប្រធានមូលនិធិ** បានជម្រាបថា មូលនិធិចិនដើម្បីសន្តិភាពនិងការអភិវឌ្ឍ បង្កើតនៅឆ្នាំ២០១១ នៅរដ្ឋធានីប៉េកាំង ក្រោមបេសកកម្មចូលរួមកសាងសន្តិភាពនិងអភិវឌ្ឍន៍ នៅបណ្តាប្រទេសជាមិត្តរបស់ចិន នៅលើពិភពលោក។  សមិទ្ធផលនិងស្នាដៃ ជាច្រើនរបស់មូលនិធិ នៅក្នុងប្រទេសកម្ពុជា ផ្តោតលើការកសាងសាលារៀន បណ្ណាល័យ មន្ទីរពេទ្យ និងការអភិវឌ្ឍភូមិជាច់ស្រយាល។ លោកស្រីបានបញ្ជាក់ថា សកម្មភាពរបស់មូលនិធិ គឺត្រូវអនុវត្តទៅតាមផែនការ៥ឆ្នាំ លើកទី១៥ របស់ចិន (២០២៦-២០៣០) ដែលសំដៅកសាងសហគមន៍ជោគវាសនារួម ប្រកបដោយសន្តិភាព និងវិបុលភាព។

ថ្លែងក្នុងឱកាសនោះ **ឯកឧត្តមបណ្ឌិត** អនុប្រធានទី២ ព្រឹទ្ធសភា បានវាយតម្លៃខ្ពស់និងសាទរចំពោះសមិទ្ធផលដែលមូលនិធិចិនដើម្បីសន្តិភាពនិងការអភិវឌ្ឍ និងមូលនិធិ Peaceland បានចូលរួមក្នុងការលើកកម្ពស់វិបុលភាពសង្គមកម្ពុជាកន្លងមក។

**ឯកឧត្តមបណ្ឌិត** អនុប្រធានទី២ ព្រឹទ្ធសភា បានលើកទឹកចិត្តមូលនិធិចិនដើម្បីសន្តិភាពនិងការអភិវឌ្ឍកសាងភូមិគំរូបន្ថែមទៀត ឱ្យបានគ្រប់ភូមិភាគទាំង៨ ដោយគួរផ្តោតលើការអប់រំកុមារ និងសុខភាព ដែលជាកត្តាគន្លឹះរុញច្រានវិបុលភាពសង្គមនាថ្ងៃអនាគត៕

ខ្លឹមសារ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា

រូបភាព៖ នាយកដ្ឋានព័ត៌មាន



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❈នាថ្ងៃចន្ទ ទី១ ខែធ្នូ ឆ្នាំ២០២៥ នៅអាកាសយានដ្ឋានអន្តរជាតិតេជោ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញថ្វាយព្រះរាជដំណើរព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្តេចយាងទៅចូលរួមកម្មវិធីបណ្ឌិត្យសភាវិទ្យាសាស្ត្រ នៅទីក្រុងប៉ារីស ប្រទេសបារាំង។



❈នារសៀលថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៥ នៅអាកាសយានដ្ឋានអន្តរជាតិតេជោ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញទទួលព្រះរាជដំណើរយាងនិវត្តន៍របស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា បន្ទាប់ពីព្រះអង្គបានយាងចូលរួមកម្មវិធីបណ្ឌិត្យសភាវិទ្យាសាស្ត្រ នៅទីក្រុងប៉ារីស ប្រទេសបារាំង។



❈នាថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុច បូររិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភា បានដឹកនាំគណៈប្រតិភូព្រឹទ្ធសភាអញ្ជើញគោរពវិញ្ញាណក្ខន្ធសព ឯកឧត្តមសាស្ត្រាចារ្យ **ហេង តៃគ្រី** រដ្ឋលេខាធិការក្រសួងសុខាភិបាល និងជាអតីតប្រធានមន្ទីរពេទ្យកាល់ម៉ែត នៅសង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។




❈នាថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា និងជាប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ បានដឹកនាំកិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។



## សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❈នាថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា និងជាប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ បានដឹកនាំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ អញ្ជើញគោរពវិញ្ញាណក្ខន្ធសព លោកវរសេនីយ៍ត្រី **ហៃន គីណា** វីរកងទ័ពឈរជើងនៅកងពលតូចលេខ៩ ក្នុងវរសេនាតូចកងពលលេខ៣៩៤ ឈរជើងប្រចាំទិសមុំបី ខេត្តព្រះវិហារ នៅភូមិបឹងកេតលើ ឃុំព្រែកកក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។



❈នាថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា និងជាប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ បានដឹកនាំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ អញ្ជើញគោរពវិញ្ញាណក្ខន្ធសព លោកជំទាវ **លី ណៃស្រ៊ន់** ភរិយារបស់ឯកឧត្តម **ខ្លូត ផន** ប្រធានក្រុមប្រឹក្សាខេត្តកំពង់ចាម នៅភូមិតាណោង សង្កាត់សំបួរមាស ក្រុងកំពង់ចាម ខេត្តកំពង់ចាម។




❈នាថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា បានអនុញ្ញាតឱ្យ ឯកឧត្តម **គី តិច** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមមេធាវីរាជរដ្ឋាភិបាល និងជាប្រធានក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោសែន ចូលជួបសម្តែងការគួរសម និងនាំយកវិភាគទានស្ម័គ្រចិត្តជូនឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា សម្រាប់ឧបត្ថម្ភដល់វីរកងទ័ពជួរមុខនិងបងប្អូនប្រជាជនភៀសសឹក។



# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❈នាព្រឹកថ្ងៃព្រហស្បតិ៍ ទី១៨ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា និងជាប្រធានក្រុមសភាជាតិកម្ពុជា នៃសភាប្រើភាសាបារាំង បានអញ្ជើញដឹកនាំកិច្ចប្រជុំក្រុមសភាជាតិកម្ពុជា APF ដើម្បីត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មការនយោបាយនៃសភាប្រើភាសាបារាំង ឆ្នាំ២០២៦ នៅព្រះរាជាណាចក្រកម្ពុជា នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។



❈នាថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា និងជាប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ បានដឹកនាំគណៈប្រតិភូក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ អញ្ជើញគោរពវិញ្ញាណក្ខន្ធសព លោកវរសេនីយ៍ត្រី **ហោង ចាន់ធឿន** លោកវរសេនីយ៍ត្រី **កេន សារ៉េត** និងលោកអនុសេនីយ៍ទោ **អ៊ិន សុខ** វីរយុទ្ធជនឈរជើងនៅសមរភូមិជួរមុខ ទិសប្រាសាទតាក្របី នៅស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។



❈នាល្ងាចថ្ងៃចន្ទ ទី១ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីជប់លៀងដំណាច់ឆ្នាំ២០២៥ របស់សមាគមអតីតនិស្សិតខ្មែរមកពីជប៉ុន (JAC) នៅរាជធានីភ្នំពេញ។




❈នាព្រឹកថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភានិងជាប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ បានដឹកនាំគណៈ-ប្រតិភូក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ អញ្ជើញគោរពវិញ្ញាណក្ខន្ធសព ឧបាសិកា **សេង យុអៀន** ម្តាយបង្កើតរបស់លោក **លឹម សុនា** អភិបាលខណ្ឌជ្រោយចង្វារ នៅឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។



# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❈នារសៀលថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំប្រចាំខែជាមួយប្រធានគណៈកម្មការទាំង១០ព្រឹទ្ធសភា ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ ប្រធានក្រុមសមាជិកា និងប្រធានគណៈកម្មការក្រមសីលធម៌សភារបស់សមាជិកព្រឹទ្ធសភា នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា តំណាងដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមក្នុងពិធីបុណ្យខួបឆ្នាំទី៣៤ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា ( ៧ ធ្នូ ១៩៩១ - ៧ ធ្នូ ២០២៥ ) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចក្រឡាហោម **ស ខេង** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅវត្តស្វាយពពែ រាជធានីភ្នំពេញ។



❈នាថ្ងៃសៅរ៍ ទី១៣ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា និងលោកជំទាវ ឯកឧត្តមបណ្ឌិត **ចែម វីឌ្យ៉ា** ឯកឧត្តមបណ្ឌិត **នាង ផាត** ឯកឧត្តម **ហេង ហាលីម** ព្រមទាំងសហការី បានអញ្ជើញចុះសួរសុខទុក្ខវីរកងទ័ពកំពុងសម្រាកព្យាបាល នៅមន្ទីរពេទ្យព្រះកេតុមាលា រាជធានីភ្នំពេញ។



# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❈នារសៀលថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា និងជាប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ បានដឹកនាំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ អញ្ជើញគោរពវិញ្ញាណក្ខន្ធសព ឧបាសក **អ៊ុក ខេមរា** ចៅសង្កាត់ទួលសង្កែទី២ នៅសង្កាត់ទួលសង្កែទី២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។



❈នាថ្ងៃសុក្រ ទី១៩ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញចុះសួរសុខទុក្ខយោធិនរបួស ដែលកំពុងសម្រាកព្យាបាលក្នុងមន្ទីរពេទ្យខេត្តកំពង់ធំ និងចែកអំណោយរួមមាន៖ អង្ករ ទឹកដោះចន្ទី អាវយឺត និងថវិកាមួយចំនួន។



❈នាថ្ងៃសុក្រ ទី១៩ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញចុះសួរសុខទុក្ខនិងនាំយកគ្រឿងឧបភោគ បរិភោគ និងសម្ភារៈប្រើប្រាស់ចាំបាច់ ព្រមទាំងថវិកាមួយចំនួន ចែកជូនជនភៀសសឹក នៅវត្តសុវណ្ណគិរី ស្រុករវៀង ខេត្តព្រះវិហារ និងនៅវត្តអូរប្រាសាទ ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ។



❈នារសៀលថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញធ្វើបទបាឋកថា ស្តីពី «គោលនយោបាយនិងឱកាស» ក្នុងវិស័យស្វាយចន្ទី ដល់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និស្សិត នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង។



# ឯកឧត្តម ម៉ម ប៊ុននាង អញ្ជើញនាំយកអំណោយរបស់ព្រឹទ្ធសភា ប្រគល់ជូនរដ្ឋបាលខេត្តតាកែវ និងខេត្តកំពត





*គណៈប្រតិភូគណៈកម្មការទី១០ព្រឹទ្ធសភា ជួបសំណេះសំណាលជាមួយអាជ្ញាធរខេត្តតាកែវ*

នាថ្ងៃសៅរ៍ ទី៦ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយនៃព្រឹទ្ធសភា (គណៈកម្មការទី១០) តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **អ៊ុច បូររិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភា អញ្ជើញនាំយកអំណោយមនុស្សធម៌របស់ព្រឹទ្ធសភា ដែលជាឱសថ ក្នុងទំហំទឹកប្រាក់សរុបជាង ពីរលានបួនសែនដុល្លារអាម៉េរិក ប្រគល់ជូនរដ្ឋបាលខេត្តតាកែវនិងខេត្តកំពត នៅមន្ទីរសុខាភិបាលខេត្តតាកែវនិងខេត្តកំពត ដោយមានការអញ្ជើញចូលរួមពី សមាជិកគណៈកម្មការទី១០ព្រឹទ្ធសភា, ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥, ឯកឧត្តម **វ៉ី សំណាង** អភិបាលខេត្តតាកែវ , ឯកឧត្តម **ខៀវ រិទ្ធិភណ្ឌ** អភិបាលរងខេត្តកំពត ព្រមទាំងអាជ្ញាធរពាក់ព័ន្ធ នៃខេត្តទាំងពីរ។

ក្នុងឱកាសនោះ **ឯកឧត្តមអភិបាលខេត្តតាកែវ** និង**ឯកឧត្តមអភិបាលរងខេត្តកំពត** បានសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម **អ៊ុច បូររិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភា និងឯកឧត្តម **ម៉ម ប៊ុននាង** ដែលបានគិតគូរដោយយកចិត្តទុកដាក់ពីសុខុមាលភាពរបស់ប្រជាជន និងខិតខំកៀរគរជំនួយពីគ្រប់ទិសទី យកមកប្រគល់ដល់រដ្ឋបាលខេត្តទាំងពីរ ដើម្បីជួយលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋក្រីក្រ និងជនងាយរងគ្រោះនៅមូលដ្ឋានខេត្តតាកែវ និងខេត្តកំពត។



*គណៈប្រតិភូគណៈកម្មការទី១០ព្រឹទ្ធសភា ប្រគល់អំណោយជូនអាជ្ញាធរខេត្តតាកែវ*

មានប្រសាសន៍សំណេះសំណាលនាឱកាសនោះ ឯកឧត្តម **ម៉ម ប៊ុននាង** បានពាំនាំនូវការផ្តាំផ្ញើការសួរសុខទុក្ខប្រកបដោយក្តីនឹករលឹកពីសំណាក់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រមុខរដ្ឋស្តីទី ឯកឧត្តម **អ៊ុច បូររិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភា ឯកឧត្តមបណ្ឌិត **ឆន់ ខឡុងនា** អនុប្រធានទី២ព្រឹទ្ធសភា ជូនចំពោះថ្នាក់ដឹកនាំខេត្ត និងប្រជាពលរដ្ឋទាំងអស់នៃខេត្ត





*គណៈប្រតិភូគណៈកម្មការទី១០ព្រឹទ្ធសភា ជួបសំណេះសំណាលជាមួយអាជ្ញាធរខេត្តកំពត*

តាកែវនិងខេត្តកំពត ព្រមទាំងបានថ្លែងនូវការកោតសរសើរចំពោះថ្នាក់ដឹកនាំខេត្តតាកែវនិងខេត្តកំពត ព្រមទាំងអាជ្ញាធរមូលដ្ឋានគ្រប់ជាន់ថ្នាក់ ដែលបានយកចិត្តទុកដាក់ក្នុងការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ពិសេសសុខុមាលភាពរបស់ប្រជាពលរដ្ឋបានយ៉ាងល្អប្រសើរ។

**ឯកឧត្តមប្រធាន** បានគូសបញ្ជាក់ថា អំណោយរបស់ព្រឹទ្ធសភាខាងលើ គឺទទួលបានពីការជួយឧបត្ថម្ភគាំទ្រពីសំណាក់ មូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ (Global Life Sharing) ដែលមានមូលដ្ឋាននៅប្រទេសកូរ៉េ។ មូលនិធិនេះដែលតែងតែផ្តល់នូវគុណតម្លៃដល់សុខុមាលភាពប្រជាជននិងតែងតែរួមចំណែកលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជន ហើយតែងតែជួយឧបត្ថម្ភជាឱសថ ឧបករណ៍វេជ្ជសាស្ត្រ និងសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃដល់បណ្តាប្រទេសជាច្រើនលើសកលលោក។ ក្នុងនោះ តាមរយៈព្រឹទ្ធសភាកម្ពុជាយើងក៏ទទួលបាននូវជំនួយមនុស្សធម៌ជាច្រើន ហើយក៏បានចែកជូនដល់ប្រជាពលរដ្ឋក្រីក្រនិងជនងាយរងគ្រោះនៅតាមបណ្តាខេត្តជាច្រើននាពេលកន្លងមក និងថ្មីៗនេះ បានជួយដល់ប្រជាជនភៀសសឹកនៅតាមបណ្តោយព្រំដែនកម្ពុជា ថៃ។

ក្នុងនាមព្រឹទ្ធសភា គណៈកម្មការទី១០ព្រឹទ្ធសភា បានចុះអនុស្សរណៈនៃការយោគយល់ជាមួយមូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ តាំងពីឆ្នាំ២០២២ ក្នុងទំហំទឹកប្រាក់ចំនួន១០លានដុល្លារអាម៉េរិកសម្រាប់រយៈពេល៥ឆ្នាំ។ ដោយមើលឃើញពីប្រសិទ្ធភាព តម្លាភាព គណនេយ្យភាពក្នុងការប្រើប្រាស់ជំនួយ នៅក្នុងឆ្នាំ២០២៤ គណៈកម្មការទី១០ព្រឹទ្ធសភា និងមូលនិធិចែករំលែកសង្គ្រោះជីវិតសកល បានពង្រីកកិច្ចសហប្រតិបត្តិការបន្ថែម តាមរយៈការចុះអនុស្សរណៈបន្តសម្រាប់រយៈពេល៥ឆ្នាំទៀត (២០២៥-២០២៩) ដែលមានទឹកប្រាក់កើនដល់ចំនួន៤០លានដុល្លារអាម៉េរិក សំដៅចូលរួមលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋក្រីក្រ និងជនងាយរងគ្រោះ នៃប្រទេសកម្ពុជាឱ្យកាន់តែប្រសើរឡើង៕



*គណៈប្រតិភូគណៈកម្មការទី១០ព្រឹទ្ធសភា ប្រគល់អំណោយជូនអាជ្ញាធរខេត្តកំពត*

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន

# ក្រុមសមាជិកាព្រឹទ្ធសភា អញ្ជើញជួបសំណេះសំណាល និងនាំយកចង្ក្រានសន្សំសំចៃថាមពលចែកជូនប្រជាពលរដ្ឋ ក្នុងស្រុកប្រាសាទបល្ល័ង្ក



*លោកជំទាវ មាន សំអាន ប្រធានក្រុមសមាជិកាព្រឹទ្ធសភា*

ក្រុមសមាជិកាព្រឹទ្ធសភា ដឹកនាំដោយលោកជំទាវ **មាន សំអាន** ប្រធានក្រុម និងជាអនុប្រធានសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ បានអញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយកចង្ក្រានសន្សំសំចៃថាមពលដែលជាអំណោយរបស់ក្រុមហ៊ុន SIPCO និងកួយ ចែកជូនប្រជាពលរដ្ឋចំនួន៣០០គ្រួសារ ព្រមទាំងអញ្ជើញនាំយកទេយ្យទាននិងបច្ច័យប្រគេនព្រះចៅអធិការវត្តពោធិ៍បក្ខីសិរីអយុធ្យា (វត្តក្រយា) ស្ថិតនៅឃុំក្រយា ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ នាព្រឹកថ្ងៃអាទិត្យ ទី៧ ខែធ្នូ ឆ្នាំ២០២៥។

ក្នុងពិធីនោះ លោកជំទាវប្រធាន បាននាំយកប្រសាសន៍ផ្តាំផ្ញើសួរសុខទុក្ខប្រកបដោយក្តីនឹករលឹកពីសំណាក់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**លោកជំទាវបណ្ឌិត** ព្រមទាំងសម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ ប្រធានសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍។

ក្នុងឱកាសនោះផងដែរ **លោកជំទាវ** បានរំលឹកអំពីខួបអនុស្សាវរីយ៍លើកទី៤៧ នៃទិវាកំណើតរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា និងអត្ថន័យនៃថ្ងៃប្រវត្តិសាស្រ្ត ២ធ្នូ ដែលជាថ្ងៃនាំសំណាងដ៏ធំធេងបំផុតដល់ប្រទេសជាតិ និងប្រជាជនកម្ពុជា គឺមានព្រឹត្តិការណ៍ជាប្រវត្តិសាស្រ្តធំៗចំនួន៣គឺៈ ១-ថ្ងៃ២ធ្នូ ឆ្នាំ១៩៧៨ ជាថ្ងៃនៃការបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ឈានទៅរំដោះជាតិ និងប្រជាជនកម្ពុជាពីរបបប្រល័យពូជសាសន៍ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩, ២-ថ្ងៃ២ធ្នូ ឆ្នាំ១៩៨៧ ជាព្រឹត្តិការណ៍ប្រវត្តិសាស្រ្ត ការចរចាជាលើកដំបូងរវាង ព្រះករុណាព្រះបាទសម្តេចព្រះ





*លោកជំទាវ មាន សំអាន សំណេះសំណាលជាមួយប្រជាពលរដ្ឋ ក្នុងស្រុកប្រាសាទបល្ល័ង្គ*

**នរោត្តម សីហនុ** និងសម្តេចតេជោ **ហ៊ុន សែន** នៅហ្វែរអង់តាជឺន័រ ប្រទេសបារាំង នាំដល់កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ឆ្នាំ១៩៩១ និងការបោះឆ្នោតឆ្នាំ១៩៩៣ និង៣-ព្រឹត្តិការណ៍ ២ធ្នូ ឆ្នាំ១៩៩៨ ថ្ងៃបង្កើតយុទ្ធសាស្ត្រត្រីកោណ បានឈានដល់ការលំរលាយនៃអង្គការចាត់តាំងនយោបាយនិងយោធារបស់ខ្មែរក្រហមក្រោមនយោបាយ ឈ្នះ ឈ្នះ! របស់សម្តេចតេជោ **ហ៊ុន សែន** នាំមកនូវសុខសន្តិភាពពេញលេញ ពាសពេញផ្ទៃប្រទេសនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨។

បន្ថែមពីនេះ **លោកជំទាវ**បានលើកឡើងអំពីសភាពការណ៍ព្រំដែន ជាពិសេសផ្លែផ្កាជាវិជ្ជមានគួរជាទីមោទនៈនៃយុទ្ធសាស្ត្រស្វាត់តែមិនស្មៀម របស់**សម្តេចតេជោ សម្តេចធិបតី** ដែលនាំកម្ពុជាឱ្យចៀសផុតនៅជំណាក់កាលនេះពីវិនាសកម្មដ៏ធំធេង ដែលកើតចេញពីសមរភូមិសង្គ្រាមរវាងកម្ពុជានិងថៃ ដោយបានដឹកដៃភាគីថៃ ចូលក្នុងសមរភូមិការទូត ដោយមានអន្តរជាតិដឹងឮ និងសមរភូមិផ្លូវច្បាប់ ដែលនេះជាសមរភូមិល្អបំផុត ដើម្បីធានាបាននូវការការពារបូរណភាពទឹកដីរបស់កម្ពុជា ដោយមិនមានការបង្ហូរឈាមនិងបានអរគុណនិងសំណូមពរឱ្យពុកម៉ែបងប្អូនទាំងអស់គ្នាជឿទុកចិត្តលើការដឹកនាំរបស់សម្តេចទាំងទ្វេ ក្នុងការនាំនាវាកម្ពុជាឆ្ពោះទៅរកសុខសន្តិភាព និងភាពជឿនលឿន។

ជាមួយគ្នានេះ **លោកជំទាវ**បានសម្តែងនូវសេចក្តីរីករាយ និងកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងយកអស់កម្លាំងកាយចិត្ត ប្រាជ្ញា ស្មារតី និងទទួលខុសត្រូវក្នុងការបំពេញភារកិច្ចការងារក្នុងរយៈពេលកន្លងមក របស់ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ នៃស្រុកប្រាសាទបល្ល័ង្គ ទទួលបានជោគជ័យគួរឱ្យកត់សម្គាល់។

អំណោយដែលបានផ្តល់ជូនប្រជាពលរដ្ឋក្នុងឱកាសនោះ ក្នុង១គ្រួសារទទួលបាន៖ នំប៉ុង ចង្ក្រានសន្សំសំចៃថាមពល ចំនួន១ និងភួយ ចំនួន១ ព្រមទាំងឧបត្ថម្ភទឹកប្រាក់ដល់ស្ត្រីមានផ្ទៃពោះចំនួន១៣នាក់ និងអនុសាខាសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ស្រុកប្រាសាទបល្ល័ង្គ៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន



*ក្រុមសមាជិកាព្រឹទ្ធសភា ប្រគល់ថវិកាជូនសាខាសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ស្រុកប្រាសាទបល្ល័ង្គ*



*ក្រុមសមាជិកាព្រឹទ្ធសភា នាំយកទេយ្យទាន និងបច្ច័យប្រគេនព្រះចៅអធិការវត្តពោធិ៍បក្ខីសិរីអែយុធ្យា*



*ក្រុមសមាជិកាព្រឹទ្ធសភា ចែកអំណោយជូនប្រជាពលរដ្ឋក្នុងស្រុកប្រាសាទបល្ល័ង្គ*

# ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ អញ្ជើញនាំយកអំណោយ ជាគ្រឿងឧបភោគ បរិភោគ ចែកជូនជនភៀសសឹកចំនួន៣ស្រុក ក្នុងខេត្តកោះកុង

នាព្រឹកថ្ងៃអង្គារ ទី១៦ ខែធ្នូ ឆ្នាំ២០២៥ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ (ខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ កោះកុង និងខេត្តព្រះសីហនុ) ដឹកនាំដោយឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានក្រុម អមដោយឯកឧត្តម



*ឯកឧត្តមបណ្ឌិត ម៉ុង ឫទ្ធី ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧*

លោកជំទាវ និងបុគ្គលិកគ្រប់ជាន់ថ្នាក់នៃក្រុមហ៊ុន ម៉ុង ឫទ្ធី គ្រុប ព្រមទាំងមានការចូលរួមពីលោកជំទាវអភិបាល លោកអភិបាលរង ឯកឧត្តមប្រធានក្រុមប្រឹក្សាខេត្ត លោកអភិបាលស្រុក និងអាជ្ញាធរមូលដ្ឋាននៃខេត្តកោះកុង បានអញ្ជើញសំណេះសំណាល សួរសុខទុក្ខ និងនាំយកជាគ្រឿង ឧបភោគ បរិភោគ ព្រមទាំងថវិកាមួយចំនួន ជូនដល់បងប្អូនជនភៀសសឹកដែលរងគ្រោះដោយសារកងកម្លាំងយោធាថៃបានបាញ់ប្រហារចូលមកក្នុងទឹកដីខេត្តកោះកុង និងកំពុងជម្លៀសខ្លួនមកស្នាក់នៅកន្លែងមានសុវត្ថិភាព តាមទីវត្តអារាម និងសាលារៀន នៅក្នុងស្រុកស្រែអំបិល ស្រុកបូទុមសាគរ និងស្រុកកោះកុង ខេត្តកោះកុង។

ក្នុងឱកាសនោះ **ឯកឧត្តមបណ្ឌិត** បានមានប្រសាសន៍ជម្រាបជូននូវការផ្តាំផ្ញើសួរសុខទុក្ខនិងការយកចិត្តទុកដាក់ខិតខំប្រឹងប្រែងរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងបានជម្រាបជូនដល់បងប្អូនប្រជាពលរដ្ឋថា ប្រមុខរាជរដ្ឋាភិបាលកម្ពុជា នៅតែបន្តស្វែងរកដំណោះស្រាយសមស្របចំពោះបញ្ហាជម្លោះព្រំដែនរវាងប្រទេសទាំងពីរ (កម្ពុជា-ថៃ) ដើម្បីការពារនិងថែរក្សាអធិបតេយ្យនិងបូរណភាពទឹកដី ហើយស្ថិតក្នុងស្ថានភាពដ៏លំបាកនេះ សូម






*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ នាំយកអំណោយជាគ្រឿងឧបភោគ បរិភោគ ចែកជូនជនភៀសសឹក នៅស្រុកស្រែអំបិល*





*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ នាំយកអំណោយជាគ្រឿងឧបភោគ បរិភោគ ចែកជូនជនភៀសសឹក នៅស្រុកបូទុមសាគរ*

ប្រជាពលរដ្ឋទាំងអស់បន្តជឿជាក់និងលើកទឹកចិត្តដល់វីរកងទ័ពដ៏អង់អាចក្លាហានរបស់យើងដែលកំពុងប្រយុទ្ធតស៊ូយ៉ាងខ្លាំងក្លានៅគ្រប់សមរភូមិទាំងអស់។ រាជរដ្ឋាភិបាល កងទ័ព និងប្រជាជនកម្ពុជាបានរួបរួមគ្នាជាធ្លុងមួយក្នុងការការពារទឹកដី សេចក្ដីថ្លៃថ្នូរ និងអធិបតេយ្យរបស់យើងដោយអង់អាចក្លាហាន និងដោយមិនងាករេជាដាច់ខាតទោះក្នុងតម្លៃណាក៏ដោយ។

ជាចុងបញ្ចប់ **ឯកឧត្តមបណ្ឌិត** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ថ្នាក់ដឹកនាំខេត្ត អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ ជាពិសេសអាជ្ញាធរស្រុកស្រែអំបិល ស្រុកបូទុមសាគរ និងស្រុកកោះកុង ខេត្តកោះកុង ដែលបានខិតខំប្រឹងប្រែងសម្របសម្រួលនិងរៀបចំទីកន្លែងស្នាក់អាស្រ័យបណ្ដោះអាសន្នជូនបងប្អូនប្រជាពលរដ្ឋបានយ៉ាងទាន់ពេលវេលាមានរបៀបរៀបរយ និងប្រកបដោយសុវត្ថិភាព ឆ្លើយតបនឹងស្ថានការណ៍ជាក់ស្ដែង និងសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ គុណកែវទាំងបី សូមតាមអភិបាលប្រោះព្រំ ឃុំគ្រងថែរក្សា និងប្រសិទ្ធពរជ័យជូនវីរយុទ្ធជនដ៏អង់អាចក្លាហាននៅតាមព្រំដែន សូមជួបតែសុខសុវត្ថិភាព និងទទួលបានជ័យជម្នះលើសមរភូមិ កម្ចាត់បច្ចាមិត្តឈ្លានពានឱ្យវិនាសអន្តរាយ៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន





*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ នាំយកអំណោយជាគ្រឿងឧបភោគ បរិភោគ ចែកជូនជនភៀសសឹក នៅស្រុកកោះកុង*

# គណៈប្រតិភូគណៈកម្មការទី៨ និងក្រុមសមាជិកាព្រឹទ្ធសភា អញ្ជើញសួរសុខទុក្ខ និងនាំយកអំណោយគ្រឿងឧបភោគ បរិភោគ សម្ភារៈប្រើប្រាស់ និងថវិកា ប្រគល់ជូនវីរកងទ័ពប្រចាំសមរភូមិមុខ និងវីរកងទ័ពរងរបួស កំពុងសម្រាកព្យាបាលជំងឺ នៅខេត្តព្រះវិហារ និងខេត្តកំពង់ធំ




*គណៈប្រតិភូគណៈកម្មការទី៨ និងក្រុមសមាជិកាព្រឹទ្ធសភា នាំយកអំណោយចែកជូនវីរកងទ័ពជួរមុខប្រចាំតំបន់អានសេះ ខេត្តព្រះវិហារ*

ក្នុងពេលដែលប្រទេសជាតិកំពុងប្រឈមជាមួយនឹងការឈ្លានពានរបស់ថៃ គណៈប្រតិភូគណៈកម្មការទី៨ព្រឹទ្ធសភា និងក្រុមសមាជិកាព្រឹទ្ធសភា ដឹកនាំដោយលោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការនិងជាប្រធានក្រុម បានអញ្ជើញនាំយកនូវព្រះរាជអំណោយ និងអំណោយរបស់សប្បុរសជន រួមមាន៖ គ្រឿងឧបភោគ បរិភោគ និងសម្ភារៈប្រើប្រាស់ចាំបាច់ ព្រមទាំងថវិកាមួយចំនួន ប្រគល់ជូនវីរកងទ័ពជួរមុខប្រចាំតំបន់អានសេះនិងប្រចាំសមរភូមិមុខនៃបញ្ជាការដ្ឋានប្រតិបត្តិការសឹករងខេត្តកំពង់ធំប្រចាំនៅតំបន់អានសេះ ខេត្តព្រះវិហារ ព្រមទាំងចុះសួរសុខទុក្ខវីរកងទ័ព ដែលកំពុងសម្រាកព្យាបាលជំងឺនៅខេត្តព្រះវិហារ និងខេត្តកំពង់ធំ កាលពីថ្ងៃទី១៩ និងថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៥។

ក្នុងឱកាសនោះ លោកជំទាវប្រធានគណៈប្រតិភូ បានជម្រាបជូននូវប្រសាសន៍ផ្ដាំផ្ញើសួរសុខទុក្ខប្រកបដោយក្ដីនឹករលឹកពីសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត** និងសម្ដេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ព្រមទាំង**ឯកឧត្តមអនុប្រធានទី១** និង**ឯកឧត្តមបណ្ឌិតអនុប្រធានទី២ព្រឹទ្ធសភា** ដែលតែងតែយកចិត្តទុកដាក់ខ្ពស់ចំពោះសុខទុក្ខរបស់វីរយុទ្ធជន ដែលបាននិងកំពុងឈរជើងយ៉ាងរឹងមាំ តស៊ូ ក្រាញននៀល




*គណៈប្រតិភូគណៈកម្មការទី៨ និងក្រុមសមាជិកាព្រឹទ្ធសភា អញ្ជើញសួរសុខទុក្ខយោធិន ដែលកំពុងសម្រាកព្យាបាលជំងឺ នៅមន្ទីរពេទ្យខេត្តកំពង់ធំ*

ប្រយុទ្ធជាមួយនឹងការឈ្លានពានរបស់ថៃ ដើម្បីការពារបូរណភាពទឹកដី និងប្រជាជនកម្ពុជា។ ជាមួយគ្នានោះ លោកជំទាវបានសម្តែងនូវការដឹងគុណចំពោះវីរភាពអង់អាចក្លាហានមោះមុតដ៏គួរឱ្យកោតស្ញប់ស្ញែងរបស់បងប្អូនវីរយុទ្ធជន ក្នុងបុព្វហេតុការពារជាតិមាតុភូមិ ព្រមទាំងបានបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ គុណកែវទាំងបី សូមតាមអភិបាល ប្រោះព្រំឃុំគ្រង ថែរក្សា និងប្រសិទ្ធពរជ័យជូនវីរយុទ្ធជនដ៏អង់អាចក្លាហាននៅតាមព្រំដែន សូមជួបតែសុខសុវត្ថិភាព ទទួលបានជ័យជម្នះលើសមរភូមិកម្ចាត់បច្ចាមិត្តឈ្លានពានឱ្យវិនាសអន្តរាយ ព្រមទាំងបានលើកទឹកចិត្តនិងសូមជូនពរដល់យោធិនដែលរងរបួសទាំងអស់ សូមឱ្យមានសុខភាពល្អមាំទាំ និងឆាប់ជាសះស្បើយ ព្រមទាំងបានថ្លែងអំណរគុណចំពោះក្រុមគ្រូពេទ្យ ដែលបានលះបង់កម្លាំងកាយ កម្លាំងចិត្ត ក្នុងការមើលថែទាំនិងព្យាបាល។



*គណៈប្រតិភូគណៈកម្មការទី៨ និងក្រុមសមាជិកាព្រឹទ្ធសភា អញ្ជើញគោរពវិញ្ញាណក្ខន្ធសពលោកពលបាលឯក រុន តារ៉ា នៅខេត្តព្រះវិហារ*

ឆ្លៀតក្នុងឱកាសនោះ គណៈប្រតិភូបានអញ្ជើញគោរពវិញ្ញាណក្ខន្ធនិងនាំយកថវិការបស់សម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ ចូលរួមរំលែកទុក្ខជាមួយនឹងក្រុមគ្រួសារសពលោកពលបាលឯក **រុន តារ៉ា** ជំនួយការចិត្តសាស្ត្រសមរភូមិជួរមុខឈរជើងនៅទិសអានសេះ ខេត្តព្រះវិហារ ដែលបានពលីជីវិតក្នុងសមរភូមិ កាលពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៥ ក្នុងជន្មាយុ៣៨ឆ្នាំ នៅស្រុកសង្គមថ្មី ខេត្តព្រះវិហារ។

ក្រៅពីចុះសួរសុខទុក្ខ និងនាំយកអំណោយជូនវីរកងទ័ព លោកជំទាវ **មាន សំអាន** បានដឹកនាំក្រុមការងាររៀបចំគ្រឿងឧបភោគ បរិភោគ និងសម្ភារៈប្រើប្រាស់ចាំបាច់ សម្រាប់យកទៅជូនវីរកងទ័ពនិងប្រជាពលរដ្ឋភៀសសឹក ក្នុងស្មារតីសាមគ្គីភាពកាន់តែរឹងមាំ រួមចំណែកលើកទឹកចិត្តដល់វីរកងទ័ពដ៏អង់អាចក្លាហានរបស់កម្ពុជា ដែលកំពុងឈរជើងក្នុងសមរភូមិប្រយុទ្ធជាមួយនឹងការឈ្លានពានរបស់ថៃ និងសម្រាលទុក្ខលំបាករបស់បងប្អូនប្រជាជនភៀសសឹក៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន





*គណៈប្រតិភូគណៈកម្មការទី៨ និងក្រុមសមាជិកាព្រឹទ្ធសភា រៀបចំវេចខ្ចប់គ្រឿងឧបភោគ បរិភោគ និងសម្ភារៈប្រើប្រាស់ចាំបាច់ សម្រាប់យកទៅប្រគល់ជូនវីរកងទ័ពជួរមុខ និងប្រជាពលរដ្ឋភៀសសឹក*

# ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ អញ្ជើញនាំយកអំណោយ ជាគ្រឿងឧបភោគ បរិភោគ ចែកជូនជនភៀសសឹក នៅស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង



ឯកឧត្តមបណ្ឌិត ម៉ុង ឫទ្ធី ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧

នាព្រឹកថ្ងៃចន្ទ ទី២២ ខែធ្នូ ឆ្នាំ២០២៥ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ (ខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ កោះកុង និងខេត្តព្រះសីហនុ) ដឹកនាំដោយ ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានក្រុមនិងលោកជំទាវ **ម៉ែន ស៊ុន ម៉ុងឫទ្ធី** អមដោយឯកឧត្តម លោកជំទាវ សប្បុរសជន បុគ្គលិកគ្រប់ជាន់ថ្នាក់នៃក្រុមហ៊ុន ម៉ុង ឫទ្ធី គ្រុប និងមូលនិធិព្រះច័ន្ទ ព្រមទាំងមានការចូលរួមពីអាជ្ញាធរគ្រប់ជាន់ថ្នាក់ក្នុងខេត្តកំពង់ឆ្នាំង បានអញ្ជើញចុះជួបសំណេះ-សំណាល សួរសុខទុក្ខ និងនាំយកនូវសម្ភារៈនិងគ្រឿងឧបភោគ បរិភោគ ជូនដល់បងប្អូនជនភៀសសឹកចំនួន៣៥០គ្រួសារ ក្នុងនោះមានគ្រួសាររើកងទ័ពចំនួន១១៩គ្រួសារ ដែលរងគ្រោះដោយសារការឈ្លានពាន និងការវាយប្រហារដ៏កំរោល ពីសំណាក់កងកម្លាំងយោធាថៃ បានជម្លៀសខ្លួនពីបណ្តាខេត្តផ្សេងៗ មកស្នាក់នៅតាមផ្ទះញាតិមិត្តនិងបងប្អូន ក្នុងស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង។

ក្នុងឱកាសនោះ **ឯកឧត្តមបណ្ឌិត** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅនិងវាយតម្លៃខ្ពស់ចំពោះអាជ្ញាធរគ្រប់ជាន់ថ្នាក់ក្នុងខេត្តកំពង់ឆ្នាំង ដែលបានខិតខំប្រឹងប្រែងសហការយ៉ាងសកម្ម ក្នុងការសម្របសម្រួលដល់បងប្អូនប្រជាពលរដ្ឋជនភៀសសឹក បានយ៉ាងទាន់ពេលវេលា និងឆ្លើយតបបានតាមតម្រូវការជាក់ស្តែងក្នុងស្ថានការណ៍ដ៏លំបាកនេះ។ ទន្ទឹមនឹងនោះ **ឯកឧត្តមបណ្ឌិត** បានជម្រាបជូននូវការផ្តាំផ្ញើសួរសុខទុក្ខ និងការយកចិត្តទុកដាក់ពីសំណាក់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី





ឯកឧត្តមបណ្ឌិត ម៉ុង ឫទ្ធី សំណេះសំណាលជាមួយជនភៀសសឹក នៅស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង




*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ នាំយកអំណោយជាគ្រឿងឧបភោគ បរិភោគ ចែកជូនជនភៀសសឹក នៅស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង*

នៃព្រះរាជាណាចក្រកម្ពុជា ជូនដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ ព្រមទាំងបានជម្រាបជូនឱ្យបងប្អូនប្រជាពលរដ្ឋរក្សាភាពស្ងប់ស្ងាត់ មានទំនុកចិត្តនិងជឿជាក់លើរាជរដ្ឋាភិបាល ដែលកំពុងខិតខំស្វែងរកដំណោះស្រាយសមស្របចំពោះបញ្ហាជម្លោះព្រំដែនរវាងប្រទេសទាំងពីរ ដោយឈរលើគោលការណ៍សន្តិវិធី ច្បាប់អន្តរជាតិ និងការការពារ បូរណភាពទឹកដី ថែរក្សាអធិបតេយ្យ និងផលប្រយោជន៍ជាតិជាអាទិភាពខ្ពស់បំផុត។

ក្រៅពីចុះសួរសុខទុក្ខជនភៀសសឹក ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ បានអញ្ជើញចូលរួមពិធីបុណ្យគម្រប់៧ថ្ងៃ សពលោកអនុសេនីយ៍ទោ **ហៃ ហ៊ីម** នាយក្រុមទី១ អនុសេនាតូច៣ អនុសេនាធំស៊ើបការណ៍កងពលតូចអន្តរាគមន៍លេខ៥ កងពលធំអន្តរាគមន៍លេខ២ ឈរជើងនៅទិសប្រាសាទតាក្របី ខេត្តឧត្តរមានជ័យ ដែលបានពលីជីវិតក្នុងសមរភូមិប្រយុទ្ធជាមួយការឈ្លានពានរបស់ថៃ កាលពីថ្ងៃអង្គារ ទី១៦ ខែធ្នូ ឆ្នាំ២០២៥ ក្នុងជន្មាយុ ៣០ឆ្នាំ។

ក្នុងឱកាសនោះផងដែរ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧និងសប្បុរសជន ក៏បានចូលបច្ច័យចំនួនពីរលានប្រាំពីរសែនរៀល និង១០០ដុល្លារ ជូនដល់គ្រួសារសព នៅភូមិត្របែក ឃុំត្រងិល ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន




*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ អញ្ជើញចូលរួមពិធីបុណ្យគម្រប់៧ថ្ងៃ សពលោកអនុសេនីយ៍ទោ ហៃ ហ៊ីម*

# កិច្ចប្រជុំគណៈកម្មការទាំង១០ ក្រុមភូមិភាគ និងក្រុមនានានៃព្រឹទ្ធសភា

## ❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី២ព្រឹទ្ធសភា ចំនួន៤លើក៖

ឯកឧត្តម **យស ផានីត្តា** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិនិត្យពិភាក្សាលើ៖

-របាយការណ៍ប្រចាំខែវិច្ឆិកានិងលើកទិសដៅបន្ត, ពិនិត្យសេចក្តីព្រាងផែនការប្រតិបត្តិឆ្នាំ២០២៦,ស្តាប់បទបង្ហាញ



របស់ក្រុមហ៊ុនធុរវឌ្ឍន៍ និងបញ្ហាផ្សេងៗ នាព្រឹកថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៥។



-ការស្រាវជ្រាវអំពីសេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ និងសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦ ជូនគណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា នារសៀលថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៥។



-ការប្រគល់ភារកិច្ចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាមកឱ្យគណៈកម្មការ ដើម្បីពិនិត្យសិក្សា ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ និងសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦ និងបញ្ហាផ្សេងៗ នារសៀលថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៥។



-របាយការណ៍ប្រចាំខែធ្នូនិងលើកទិសដៅការងារបន្តក្នុងឆ្នាំ២០២៦ និងបញ្ហាផ្សេងៗ នាព្រឹកថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៥។

## ❈កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី១) ចំនួន១លើក

នាថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **យស ផានីត្តា** ប្រធានក្រុម បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី១) ដើម្បីពិនិត្យពិភាក្សានិងត្រៀមមានយោបល់លើសេចក្តីព្រាងច្បាប់ចំនួន៣ ស្តីពី៖

១-ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤

២-ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦

៣-ការអនុម័តយល់ព្រមលើ៖

១-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាធិប-



តេយ្យប្រជាមានិតឡាវស្តីពី ការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូលនិងការបង្ការការគេចវេះពន្ធនិងការចៀសវាងពន្ធ

២-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋហ្វីលីពីនស្តីពី ការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូលនិងការបង្ការការគេចវេះពន្ធនិងការចៀសវាងពន្ធ

៣-ពិធីសារទី២ ដើម្បីធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋសិង្ហបុរីស្តីពី ការចៀសវាងការយកពន្ធត្រួតគ្នានិងការបង្ការការកិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល។

### ❈កិច្ចប្រជុំជាមួយតំណាងរាជរដ្ឋាភិបាល ចំនួន២លើក៖



ឯកឧត្តម **យស ផានីត្តា** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំរវាងគណៈកម្មការទាំង១០របស់ព្រឹទ្ធសភា ជាមួយតំណាងរាជរដ្ឋាភិបាល ដឹកនាំដោយឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦ និងសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា នាព្រឹកថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៥។

### ❈កិច្ចប្រជុំអន្តរសភាប្រើភាសាបារាំង (APF) ចំនួន១លើក

នាថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **យស ផានីត្តា**



ប្រធាន និងឯកឧត្តម **ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំអនុគណៈកម្មការនៃបណ្តាញសមាជិកសភាប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតសកលនៃសភាប្រើភាសាបារាំង (APF) តាមប្រព័ន្ធនិម្មិតដែលផ្សាយចេញពីទីក្រុងប៉ារីស នៃសាធារណរដ្ឋបារាំង ពីម៉ោង១៣:០០នាទី ដល់ម៉ោង១៧:០០នាទី។

### ❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៣ព្រឹទ្ធសភា ចំនួន១លើក

នាថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ម៉ុខ ឫទ្ធី**



ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការដើម្បីពិនិត្យពិភាក្សាលើរបាយការណ៍សកម្មភាពការងារប្រចាំខែធ្នូ ឆ្នាំ២០២៥ និងទិសដៅការងារខែមករា ឆ្នាំ២០២៦, របាយការណ៍លទ្ធផលការងារប្រចាំឆ្នាំ២០២៥, របាយការណ៍ថវិកាប្រចាំឆ្នាំ២០២៥, ផែនការសកម្មភាពប្រចាំឆ្នាំ២០២៦ និងបញ្ហាផ្សេងៗ។

### ❈កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី២) ចំនួន១លើក

នាថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ម៉ុខ ឫទ្ធី** អនុប្រធានក្រុម បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី២) ដើម្បីពិនិត្យពិភាក្សានិងត្រៀមមានយោបល់លើសេចក្តីព្រាងច្បាប់ចំនួន៣ ស្តីពី៖

១-ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រង





ឆ្នាំ២០២៤

២-ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦

៣-ការអនុម័តយល់ព្រមលើ៖

១-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវស្តីពី ការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូលនិងការបង្ការការគេចវេះពន្ធនិងការចៀសវាងពន្ធ

២-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋហ្វីលីពីនស្តីពី ការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូលនិងការបង្ការការគេចវេះពន្ធនិងការចៀសវាងពន្ធ

៣-ពិធីសារទី២ ដើម្បីធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋសិង្ហបុរីស្តីពី ការចៀសវាងការយកពន្ធត្រួតគ្នានិងការបង្ការការកិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល។

៤-ចាត់តំណាងក្រុមឡើងមានយោបល់ក្នុងសម័យប្រជុំលើកទី៤ ព្រឹទ្ធសភានីតិកាលទី៥។

**❈គណៈកម្មការទី៣ព្រឹទ្ធសភា ជួបភៀវអន្តរជាតិ ចំនួន២លើក៖**

ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការ បានទទួលជួបពិភាក្សាការងារជាមួយ៖

-គណៈប្រតិភូក្រុមហ៊ុនជប៉ុន FOREX SENDAI ដឹកនាំដោយលោក OSHIMA YOSHIKAZU ប្រធានក្រុមហ៊ុន Oshima LLC និងលោក KARINO KEIICHI ប្រធានក្រុមហ៊ុនFOREX SENDAIតាមប្រព័ន្ធនិម្មិតក្នុងគោលបំណងសិក្សាលទ្ធភាពវិនិយោគបង្កើតរោងចក្រផលិតជីកំប៉ុសជីសរីរាង្គប្រកបដោយគុណភាពខ្ពស់ និងតម្លៃសមរម្យនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅសាលប្រជុំពិសេសខាងក្រោមវិមានព្រឹទ្ធសភា នារសៀលថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៥។

-គណៈប្រតិភូក្រុមហ៊ុនជប៉ុន FUJIURA LTD ដឹកនាំដោយលោក SHOZO WATANABE ប្រធានក្រុមហ៊ុន FUJIURA LTD និងលោក KUROKAWA MAKOTO ទីប្រឹក្សាជាន់ខ្ពស់ក្រុមហ៊ុន D.C.O.N Development ក្នុងគោលបំណងសិក្សាអំពីឱកាសវិនិយោគចំណុចសក្តានុពលធំៗរបស់កម្ពុជារួមមាន៖ អាកាសធាតុ ភូមិសាស្ត្រ ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ កំពង់ផែមាត់សមុទ្រ និងជ្រើសរើសដៃគូពាណិជ្ជករក្នុងស្រុក ដើម្បីរួមគ្នាអភិវឌ្ឍដំណាំកសិកម្មនិងកសិ-ឧស្សាហកម្មកែច្នៃនាំចេញទៅទីផ្សារប្រទេសជប៉ុនវិញ នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា នារសៀលថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៥។

**❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៥ព្រឹទ្ធសភា ចំនួន៤លើក៖**

ឯកឧត្តមបណ្ឌិត **ចែម វីឌ្យា** ប្រធានគណៈកម្មការទី៥បានដឹកនាំកិច្ចប្រជុំដូចខាងក្រោម៖



-កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ នាថ្ងៃទី១ និងថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៥ ដើម្បីពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើ៖

១-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រ

កម្ពុជានិងរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវស្តីពី ការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធនិងការចៀសវាងពន្ធ

២-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាល នៃសាធារណរដ្ឋហ្វីលីពីនស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូលនិងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ

៣-ពិធីសារទី២ ដើម្បីធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាល នៃសាធារណរដ្ឋសិង្ហបុរីស្តីពី ការចៀសវាងការយកពន្ធត្រួតគ្នានិងការបង្ការការកិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល។



-កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ នារសៀលថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៥ ដើម្បីពិនិត្យពិភាក្សាលើ៖

១-ការបូកសរុបរបាយការណ៍សកម្មភាពការងារប្រចាំខែវិច្ឆិកា ឆ្នាំ២០២៥

២-ផែនការប្រតិបត្តិ ឆ្នាំ២០២៦

៣-បញ្ហាផ្សេងៗ។

-កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ នារសៀលថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៥ ដើម្បីពិនិត្យពិភាក្សាលើ៖

១-សេចក្តីរាយការណ៍ស្តីពី វឌ្ឍនភាពទំនាក់ទំនងវិស័យការទូតសភា ប្រចាំឆ្នាំ២០២៥ និងទិសដៅបន្ត

២-ការបូកសរុបរបាយការណ៍សកម្មភាពការងារប្រចាំខែធ្នូ និងប្រចាំឆ្នាំ២០២៥

៣-ការបូកសរុបចំណូល-ចំណាយថវិកាប្រចាំខែធ្នូ ឆ្នាំ២០២៥ និងប្រចាំឆ្នាំ២០២៥



៤-បញ្ហាផ្សេងៗ។

## ❋កិច្ចប្រជុំជាមួយតំណាងរាជរដ្ឋាភិបាល ចំនួន១លើក



នាថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ចែម ទីឌ្យ៉ា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំរវាងគណៈកម្មការទាំង១០របស់ព្រឹទ្ធសភា ជាមួយតំណាងរាជរដ្ឋាភិបាល ដឹកនាំដោយឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើ៖

១-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវស្តីពី ការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធនិងការចៀសវាងពន្ធ

២-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាល នៃសាធារណរដ្ឋហ្វីលីពីនស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូលនិងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ

៣-ពិធីសារទី២ ដើម្បីធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀង

វាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាល នៃសាធារណរដ្ឋសិង្ហបុរីស្តីពី ការចៀសវាងការយកពន្ធត្រួតគ្នានិងការបង្ការការគិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល។

**❋កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៣) ចំនួន១លើក**



នាថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ចែម វីយ៉ា** ប្រធានក្រុមបានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៣) ដើម្បីពិនិត្យពិភាក្សានិងត្រៀមមានយោបល់ក្នុងសម័យប្រជុំលើកទី៤ព្រឹទ្ធសភា នីតិកាលទី៥ លើសេចក្តីព្រាងច្បាប់ចំនួន៣ ស្តីពី៖

១-ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤

២-ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦

៣-ការអនុម័តយល់ព្រមលើ៖

- ១-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវស្តីពី ការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូលនិងការបង្ការការគេចវេះពន្ធនិងការចៀសវាងពន្ធ
- ២-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋហ្វីលីពីន ស្តីពី ការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូលនិងការបង្ការការគេចវេះពន្ធនិងការចៀសវាងពន្ធ
- ៣-ពិធីសារទី២ ដើម្បីធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋសិង្ហបុរីស្តីពី ការចៀសវាងការយកពន្ធត្រួតគ្នានិងការបង្ការការគិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល។

**❋កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៧ព្រឹទ្ធសភា ចំនួន១លើក**

នាថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **ឈិត សុខុន** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ



ដើម្បីស្តាប់របាយការណ៍ស្តីពី លទ្ធផលការងារប្រចាំខែធ្នូ ឆ្នាំ២០២៥ និងទិសដៅការងារខែមករា ឆ្នាំ២០២៦, ស្តាប់របាយការណ៍ ស្តីពីលទ្ធផលការងារប្រចាំឆ្នាំ២០២៥និងបញ្ហាផ្សេងៗ។

**❋កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៨ព្រឹទ្ធសភា ចំនួន១លើក**



នាថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៥ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិនិត្យពិភាក្សាលើការបូកសរុបលទ្ធផលការងារប្រចាំខែធ្នូ និងប្រចាំឆ្នាំ២០២៥, លទ្ធភាពនៃការឧបត្ថម្ភរបស់គណៈកម្មការជាគ្រឿងឧបភោគ បរិភោគ សម្ភារៈប្រើប្រាស់ និងថវិកា ជួយដល់កងកម្លាំងប្រដាប់អាវុធនិងបងប្អូនជនភៀសសឹក តាមប្រសាសន៍ដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៥ និងបញ្ហាផ្សេងៗ។

### ❋កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៤) ចំនួន១លើក



នាថ្ងៃព្រហស្បតិ៍ ទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៥ លោកជំទាវ **មាន សំអាន** ប្រធានក្រុម បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុម៤) ដើម្បីពិនិត្យពិភាក្សានិងត្រៀមមានយោបល់ក្នុងសម័យប្រជុំលើកទី៤ព្រឹទ្ធសភា នីតិកាលទី៥ លើសេចក្តីព្រាងច្បាប់ ស្តីពី៖

១-ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤

២-ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦

៣-ការអនុម័តយល់ព្រមលើ៖

- ១-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវស្តីពី ការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូលនិងការបង្ការការគេចវេះពន្ធនិងការចៀសវាងពន្ធ
- ២-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋហ្វីលីពីន ស្តីពី ការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូលនិងការបង្ការការគេចវេះពន្ធនិងការចៀសវាងពន្ធ
- ៣-ពិធីសារទី២ ដើម្បីធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋសិង្ហបុរីស្តីពី ការចៀសវាងការយកពន្ធត្រួតគ្នានិងការបង្ការការកិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល។

### ❋កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៩ព្រឹទ្ធសភា ចំនួន១លើក

នាព្រឹកថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុំ សារិទ្ធ** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីស្តាប់បទបង្ហាញរបស់អគ្គនាយកដ្ឋានស្រាវជ្រាវអំពី



សេចក្តីព្រាងច្បាប់ស្តីពី អាកាសចរណ៍ស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា, ពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន៤ និងបញ្ហាផ្សេងៗ។

### ❋កិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិសភាប្រើភាសាបារាំង (APF) ចំនួន១លើក



នាថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុំ សារិទ្ធ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិសភាប្រើភាសាបារាំង (APF) តាមប្រព័ន្ធនិម្មិត ដើម្បីចែករំលែកព័ត៌មានបឋមសម្រាប់កិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិ APF ដែលនឹងប្រព្រឹត្តទៅនៅចុងខែមករា ឆ្នាំ២០២៦ នៅសាលប្រជុំពិសេស២ វិមានព្រឹទ្ធសភា។

### ❋កិច្ចប្រជុំគណៈកម្មការក្រុមសីលធម៌សភា ចំនួន១លើក



នាថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុំ សារឹទ្ធ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា បានចូលរួមសិក្ខាសាលា ស្តីពីការផ្លាស់ប្តូរការអនុវត្តជាក់ស្តែងលើប្រធានបទ ស្តីពីសញ្ញាណនៃផលប្រយោជន៍ផ្ទាល់ខ្លួន តាមប្រព័ន្ធនិម្មិត ក្រោមការសម្របសម្រួលរបស់លោកស្រី Élodie Gagné-LAFRANCE មេធាវី-អ្នកសម្របសម្រួលសម្រាប់ការបង្ការ នៅអមស្នងការក្រមសីលធម៌ នៃរដ្ឋសភាកេបិច ប្រទេសកាណាដា នៅសាលប្រជុំពិសេស២ វិមានព្រឹទ្ធសភា។

### ❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី១០ព្រឹទ្ធសភា ចំនួន១លើក

នាថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិនិត្យសម្រេចលើសេចក្តីព្រាងរបាយការណ៍ ស្តីពីសកម្មភាពលទ្ធផលការងារប្រចាំខែធ្នូនិងប្រចាំឆ្នាំ២០២៥ និងលើកទិសដៅការងារបន្ត។

### ❈កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា ប្រចាំភូមិភាគទី៣ ចំនួន១លើក



នាថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានក្រុម បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា ប្រចាំភូមិភាគទី៣ ដើម្បីពិនិត្យសម្រេចលើផែនការប្រតិបត្តិ ប្រចាំឆ្នាំ២០២៦និងគម្រោងចុះជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ នៃ១៣ក្រុង ស្រុក ទូទាំងខេត្តកណ្តាល នៅចន្លោះសម័យប្រជុំលើកទី៤ និងលើកទី៥។

### ❈កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា ប្រចាំភូមិភាគទី៤ ចំនួន១លើក



នារសៀលថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **ម៉ុល លឹម** ប្រធានក្រុម បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា ប្រចាំភូមិភាគទី៤ ដើម្បីពិនិត្យពិភាក្សាលើផែនការប្រតិបត្តិ ប្រចាំឆ្នាំ២០២៦ និងបញ្ហាផ្សេងៗ។

### ❈កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា ប្រចាំភូមិភាគទី៥ ចំនួន១លើក



នាថ្ងៃពុធ ទី៥ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **ឈួន ឆាម** អនុប្រធានក្រុម បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ ដើម្បីពិនិត្យពិភាក្សាលើរបាយការណ៍សកម្មភាពប្រចាំឆ្នាំ២០២៥ និងលើកទិសដៅការងារបន្ត ឆ្នាំ២០២៦, ផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៦, ត្រៀមលក្ខណៈចូលរួមជាមួយគណៈកម្មការទី១០ព្រឹទ្ធសភា សម្រាប់ពិធីប្រគល់-ទទួលអំណោយមនុស្សធម៌របស់មូលនិធិសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ ជូនរដ្ឋបាលខេត្តតាកែវ និងខេត្តកំពត ព្រមទាំងបញ្ហាផ្សេងៗ៕

## ការទទួលពាក្យបណ្តឹង

❈ក្នុងខែធ្នូ ឆ្នាំ២០២៥ គណៈកម្មការទី១ព្រឹទ្ធសភា បានទទួលពាក្យបណ្តឹងចូលចំនួន៦បណ្តឹង បញ្ជូនពាក្យបណ្តឹងចេញទៅក្រសួង ស្ថាប័ន និងខេត្តពាក់ព័ន្ធចំនួន១១បណ្តឹង កំពុងពិនិត្យសិក្សាចំនួន២បណ្តឹង តម្កល់ទុកមិនចាត់ការចំនួន១បណ្តឹង ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីស្ថាប័នពាក់ព័ន្ធចំនួន៣បណ្តឹង ផ្តល់ព័ត៌មានទៅម្ចាស់បណ្តឹងចំនួន១៥បណ្តឹង ទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការចំនួន១៤បណ្តឹង៕

# សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារ នៅតាមបណ្តាភូមិភាគទាំង៨



❈នាថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **យស ផានីត្ថា** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញនាំយកអង្ករចំនួន១០តោន ថ្នាំពេទ្យ អំបុកស្រូវថ្មី ថវិកា និងសម្ភារៈចាំបាច់មួយចំនួនប្រគល់ជូនរដ្ឋបាលខេត្តព្រះវិហារ ដើម្បីចាត់ចែងប្រគល់ជូនជនភៀសសឹក និងវីរកងទ័ពកម្ពុជា ព្រមទាំងបន្តចុះសួរសុខទុក្ខជនភៀសសឹក នៅវត្តបាក់កាំ ខេត្តព្រះវិហារ។

❈ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញ៖



-ឧបត្ថម្ភអំណោយជាធុងដាក់ទឹកចំណុះ១ពាន់លីត្រ ចំនួន៥៦ធុង តាមរយៈលោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា សម្រាប់ចែកជូនវីរយុទ្ធជនជួរមុខ និងប្រជាពលរដ្ឋសម្រាប់ដាក់ទឹកប្រើប្រាស់ នៅខេត្តឧត្តរមានជ័យ នាព្រឹកថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៥។

-ជួបសំណេះសំណាលជាមួយបងប្អូនប្រជាពលរដ្ឋដែលប្រកបរបរនេសាទ នៅភូមិឫទ្ធី១ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នាព្រឹកថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៥។

-ដឹកនាំក្រុមការងារបច្ចេកទេសមកពិនិត្យសកម្មភាពក្រុមគ្រឿងចក្រស្ដាបនាគ្រឹះក្រោមនិងចាក់ក្រាលថ្មមិចM30 នៅលើផ្លូវប្រវែង១.២៥០ម៉ែត្រ ស្ថិតក្នុងភូមិស្វាយដង្គុំ ឃុំស្គុះ ដែលតភ្ជាប់មកពីភូមិព្រៃខ្យា ឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ មានប្រវែងសរុប៣.៥០០ម៉ែត្រ នារសៀលថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៥។

-ឧបត្ថម្ភជ្រូករស់ចំនួន៥ក្បាល ស្មើនឹង៥០០គីឡូក្រាម តាមរយៈលោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាសម្រាប់ចែកជូនកងពលតូចអន្តរាគមន៍លេខ៩ នៅភូមិសែនរុងរឿង១ ឃុំទឹកក្រហម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ព្រមទាំងឧបត្ថម្ភជ្រូករស់ចំនួន១០ក្បាល ស្មើនឹង១.០០០គីឡូក្រាម តាមរយៈក្រុមការងារសម្រាប់យកទៅកាប់ចែកជូនវីរយុទ្ធជន ព្រមទាំងប្រជាពលរដ្ឋដែលកំពុងតែជួបការលំបាកខ្វះស្បៀងអាហារ នៅភូមិព្រៃចាន់និងភូមិជោគជ័យ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ នារសៀលថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៥។



-ដឹកនាំក្រុមការងារបច្ចេកទេសសំណង់ ចុះពិនិត្យសកម្មភាពក្រុមការងារគ្រឿងចក្រកាយដីបណ្ដោយ១៤០ម៉ែត្រ និងទទឹង៩០ម៉ែត្រ រៀបចំទីតាំងសាងសង់រោងចក្រផលិតជីសរីរាង្គ ដែលមានកម្លាំងផលិតបានប្រមាណជា១០០តោនក្នុងមួយថ្ងៃ នៅភូមិស្វាយដង្គុំ ឃុំស្គុះ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៥។



-ជួបសំណេះសំណាល សួរសុខទុក្ខ និងណែនាំដល់កម្មករអំពីរបៀបថែទាំដំណាំស្វាយ និងដំណាំខ្នុរ នៅភូមិម៉ុងឫទ្ធីសែនជ័យ ឃុំសែនដី ព្រមទាំងដឹកនាំក្រុមការងារ ចុះពិនិត្យ

ម៉ាស៊ីនកិនកម្ទេចឈើ សម្រាប់យកមកផលិតជាជីធម្មជាតិ និងពិនិត្យសកម្មភាពក្រុមការងារគ្រឿងចក្រ ដែលបាននិងកំពុងសម្រុកសាងសង់គ្រឹះផ្លូវមួយខ្សែទទឹង៩ម៉ែត្រនិងបណ្ដោយ៣.២០០ម៉ែត្រ ព្រមទាំងពិនិត្យសកម្មភាពក្រុមជាងចាក់បេតុងក្រាលផ្លូវមួយខ្សែ កម្រាស់០,១៥សង់ទីម៉ែត្រ ដែលមានទទឹង៩ម៉ែត្រ និងបណ្ដោយ៩៥០ម៉ែត្រ នៅភូមិស្វាយជង្ហុំ ឃុំស្ដុះ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៥។



❋នារសៀលថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា បានដឹកនាំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ អញ្ជើញចូលរួមពិធីបុណ្យគម្រប់៧ថ្ងៃ សពលោកឧត្តមសេនីយ៍ត្រី **ឃួន ស៊ីង** នាយទាហាន នៃអង្គភាពកងអន្តរាគមន៍២១០ ចំណុះបញ្ជាការដ្ឋានអង្គរក្ស នៅភូមិក្បាលថ្នល់ ឃុំកក់ ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ។

❋នាព្រឹកថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុំ សារិទ្ធ** ប្រធាន និងឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈ-កម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីបញ្ចុះបឋមសិលាសាងសង់អគារ និងសមិទ្ធផលនានា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណា-ចក្រកម្ពុជា នៅឃុំសំបួរ ស្រុកស្វាយទាប ខេត្តស្វាយរៀង។




❋នាថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៥ នៅក្រុងតាខ្មៅ ខេត្តកណ្ដាល ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា និងឯកឧត្តម **ប្រាក់ ចំរើន** អនុប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញចូលរួមរំលែកទុក្ខ និងគោរពវិញ្ញាណក្ខន្ធសព ឯកឧត្តមឧត្តមសេនីយ៍ត្រី **សួន ប្រុស** វីរយុទ្ធជន ដែលបានពលីជីវិតក្នុងសមរភូមិប្រយុទ្ធជាមួយការឈ្លានពានរបស់ថៃ។

❋នារសៀលថ្ងៃសៅរ៍ ទី១៣ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា និងលោកជំទាវបណ្ឌិត **ចាន់ សុផ្លាវី** ប្រធានគណៈកម្មការ



ទី៦ព្រឹទ្ធសភា បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសព លោកវរសេនីយ៍ត្រី **ណាត់ ស៊ីជឹង** វីរយុទ្ធជន ដែលបានពលីជីវិតក្នុងសមរភូមិប្រយុទ្ធជាមួយការឈ្លានពានរបស់ថៃ នៅឃុំពោធិ៍បាន ស្រុកកោះធំ ខេត្តកណ្ដាល។



❋នាព្រឹកថ្ងៃសៅរ៍ ទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ព្រឹទ្ធសភា និងឯកឧត្តម **ទឹម ផន** លេខាធិការគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីបុណ្យបញ្ចុះខណ្ឌសីមាព្រះវិហារវត្តកំចាយមារ ក្រោមអធិបតីភាពឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងលោកជំទាវ នៅស្រុកកំចាយមារ ខេត្តព្រៃវែង។

❋ឯកឧត្តម **ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមពិធីបញ្ចុះបឋមសិលាសាងសង់អគាររដ្ឋបាល នៅឃុំកោះចេក ស្រុកពាមជរ ខេត្តព្រៃវែង ក្រោមអធិបតីភាពឯកឧត្តម **ជា សុមេធី** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីត

យុទ្ធជន និងយុវនារីតិសម្បទា នាល្ងាចថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៥។

-ចូលរួមសម្ពោធសមិទ្ធផលនានាក្នុងស្រុកកញ្ជៀច ខេត្តព្រៃវែង ក្រោមអធិបតីភាពឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នាព្រឹកថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២៥។

❈នាថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **អាយ ខន** អនុប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាជាមួយអភិបាលស្រុកកោះកុង ស្រុកបូទុមសាគរ និងស្រុកស្រែអំបិល ខេត្តកោះកុង អំពីការរៀបចំជំរំសុវត្ថិភាពជូនជនភៀសសឹកពីតំបន់ព្រំដែន និងបានឧបត្ថម្ភថវិកាមួយចំនួន។

❈ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញ៖



-ជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាសង្កាត់ នាយ-ប៉ុស្តិ៍នគរបាលរដ្ឋបាល ប្រធានភូមិទាំង១៣ និងប្រជាការពារ ព្រមទាំងបានឧបត្ថម្ភម្សៅទឹកដោះគោ ដែលលាបការពារស្បែក ដែលបិតក្បាលការពារគ្រុនក្តៅ សំពត់សម្រាប់កុមារី និងថវិកាមួយចំនួន នៅសង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៥។



-ចូលរួមជាមួយក្រុមប្រឹក្សាសង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដើម្បីទទួលអំណោយពីបងប្អូនសប្បុរសជននានា សម្រាប់យកទៅឧបត្ថម្ភជូនវីរកងទ័ពជួរមុខ និងបងប្អូនភៀសសឹកតាមបណ្តោយព្រំដែន នាថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៥។



-នាំយកអំណោយផ្ទាល់ខ្លួនរួមមាន៖ អង្ករ មី កន្សែង-ពោះគោ ចូលរួមជាមួយក្រុមប្រឹក្សាសង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ សម្រាប់យកទៅឧបត្ថម្ភជូនវីរកងទ័ពជួរមុខ និងបងប្អូនភៀសសឹកតាមបណ្តោយព្រំដែន នាថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៥។

❈ឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញ៖

-ជួបសំណេះសំណាល ពិភាក្សាការងារ និងឧបត្ថម្ភថវិកាមួយចំនួន ដល់ក្រុមប្រឹក្សាឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៥។

-ចូលរួមជាគណៈអធិបតីក្នុងពិធីមិទ្ទីញអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤៧ ទិវាកំណើតរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា ២ធ្នូ ឆ្នាំ២០២៥ ព្រមទាំងបានឧបត្ថម្ភថវិកាមួយចំនួនជូនរដ្ឋបាលឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២៥។

❈ឯកឧត្តម **ស៊ាក ឡេង** អនុប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា និងឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមជាគណៈអធិបតីក្នុងពិធីបើកបវេសនកាលឆ្នាំសិក្សា២០២៥-២០២៦ ក្រោមអធិបតីភាពឯកឧត្តម **ខង សូត** អនុប្រធានទី២រដ្ឋសភា នៅសាកលវិទ្យាល័យ **ហេង សំរិន** ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៥។

❈ឯកឧត្តម **គិន ណែត** លេខាធិការគណៈកម្មការទី២



ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមពិធីសម្ពោធឆ្លងសមិទ្ធផលនានានិងស្រោចស្រពសុគន្ធវារីប្រគេនព្រះគ្រូចៅអធិការ ព្រះគ្រូសូត្រស្តាំ ព្រះគ្រូសូត្រឆ្វេង នៃវត្តកោះអណ្តែត ស្រុកកោះអណ្តែត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេច **ឃឹម សន** ព្រះសង្ឃនាយករងទី៣ និងឯកឧត្តមបណ្ឌិត **ជា វ៉ាន់ដេត** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ នៅខេត្តតាកែវ នាព្រឹកថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៥។

-ចូលរួមក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារស្រុកកោះ-អណ្តែត ដើម្បីពិនិត្យលើសមិទ្ធផលការងារប្រចាំឆ្នាំ២០២៥ បញ្ហាប្រឈម និងដំណោះស្រាយ ព្រមទាំងត្រៀមផែនការសម្រាប់អនុវត្តឆ្នាំ២០២៦ នៅខេត្តតាកែវ នារសៀលថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៥។



❈នាព្រឹកថ្ងៃសៅរ៍ ទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **ឆាយ ឫទ្ធិសែន**

-ចូលរួមក្នុងពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤៧ ទិវាកំណើតរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា (២ ធ្នូ ១៩៧៨-២ ធ្នូ ២០២៥) នៅឃុំគគីសោម ស្រុកស្វាយទាប ខេត្តស្វាយរៀង នាថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២៥។

-ចូលរួមក្នុងពិធីបុណ្យខួបគម្រប់៧ថ្ងៃ សពលោក **រត្ន័ ខណ្ឌ:** ជាវីរកងទ័ពជួរមុខនៅព្រំដែនកម្ពុជា-ថៃ ដែលបានពលីជីវិតដោយសារផ្សែងពុលរបស់ទាហានឈ្លានពានថៃ នៅឃុំតាសួស ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង នាថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៥។

❈ឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈ-កម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញ៖

-អមដំណើរឯកឧត្តម **កែ គឹមយ៉ាន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះពិនិត្យអាងទឹក



សូរិយា ដើម្បីរៀបចំតំបន់នេះឱ្យទៅជាតំបន់ទេសចរណ៍ប្រកបដោយអនាម័យ បរិស្ថាន និងសោភណភាពស្រស់បំព្រង ព្រមទាំងការងារបោះបង្គោលព្រំចំណីអាងឱ្យបានត្រឹមត្រូវ និងបានឧបត្ថម្ភសារុងនិងថវិកាមួយចំនួនជូនដល់នគរបាល និងប្រជាការពារ នៅសង្កាត់និមិត្ត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ នាថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៥។

-នាំយកអំណោយរបស់ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ និងលោកប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តបន្ទាយមានជ័យ រួមមាន៖ មីជាតិ និងទឹកបរិសុទ្ធ ជូនដល់វីរកងទ័ពរថក្រោះអគ្គបញ្ជាការដ្ឋានជួរមុខទិសភូមិភាគទី៥ និងវីរកងទ័ពកាំភ្លើងធំអគ្គបញ្ជាការដ្ឋានជួរមុខ ខេត្តបន្ទាយមានជ័យ នាថ្ងៃទី១០ ខែធ្នូ ឆ្នាំ២២៥។



❈នាព្រឹកថ្ងៃសៅរ៍ ទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **ឆាយ វណ្ណា** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញចុះសួរសុខទុក្ខ និងនាំយកមី ទឹកត្រី និងសារុងចែកជូនបងប្អូនប្រជាពលរដ្ឋ នៅភូមិឈើទាលតូច ឃុំពាមជីលាំង ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

❈ឯកឧត្តមបណ្ឌិត **គឹម ឆា** លេខាធិការគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញ៖



-ចូលរួមរំលែកទុក្ខដល់គ្រួសារសព លោកស្រី **នង សានី** ជំទប់ទី១ នៅឃុំឈើទាល ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ព្រមទាំងបាននាំយកបច្ច័យមួយចំនួន និងភេសជ្ជៈ ជូនដល់គ្រួសារសព នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៥។

-អមដំណើរឯកឧត្តម **កែ គឹមយ៉ាន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញចុះសួរសុខទុក្ខប្រជាពលរដ្ឋសម្រាកព្យាបាលជំងឺនៅមន្ទីរពេទ្យបង្អែកស្រុកព្រះនេត្រព្រះនិងប្រជាពលរដ្ឋភៀសសឹកនៅវត្តប៉ោយចារ ឃុំប៉ោយចារ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ ព្រមទាំងបានឧបត្ថម្ភគ្រឿងឧបភោគ បរិភោគ និងថវិកាមួយចំនួន នាថ្ងៃទី១២ និងថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៥។



-ជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយកអំណោយជាសម្ភារៈ គ្រឿងឧបភោគ បរិភោគ និងថវិកាមួយចំនួនជូនដល់ជនភៀសសឹក នៅអនុវិទ្យាល័យសារង្គមណ្ឌល វត្តផ្លាស់កង់ និងអង្គភាពរថក្រោះអគ្គបញ្ជាការជួរមុខប្រចាំទិសភូមិភាគទី៥ អង្គភាពកាំភ្លើងធំអគ្គបញ្ជាការ ជួរមុខស្រុកព្រះនេត្រព្រះ ព្រមទាំងសួរសុខទុក្ខ និងនាំយកថវិកាមួយចំនួនជូនបងប្អូនដែលសម្រាកព្យាបាលជំងឺ នៅមន្ទីរពេទ្យបង្អែកស្រុកព្រះនេត្រព្រះ និងមន្ទីរពេទ្យមិត្តភាពកម្ពុជា-ជប៉ុន ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ នាថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៥។



-នាំយកអំណោយរបស់ឯកឧត្តម **កែច អូម៉ាលីស្ស** រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួមមាន៖ ម៉ាស់ការពារផ្សែងពុល អំបុក ទឹកក្រូច ជូនដល់វីរ-កងទ័ពអង្គភាពរថក្រោះអគ្គបញ្ជាការដ្ឋានជួរមុខ ប្រចាំទិសភូមិភាគទី៥ និងវីរកងទ័ពអង្គភាពកាំភ្លើងធំអគ្គបញ្ជាការដ្ឋានជួរមុខ ខេត្តបន្ទាយមានជ័យ នាថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៥។

-នាំយកអំណោយសប្បុរសធម៌របស់អ្នកភូមិនៅបុរីអ័រគីដេ



ទី២ រាជធានីភ្នំពេញ រួមមាន៖ ឆាសៀង សាច់ជ្រូកលីង សាច់ក្រក ត្រីងៀត បាក់យ៉ុង ឆៃប៉ូវ បាយក្តាំងសាច់ជ្រូក បាយដំណើបសាច់ជ្រូក និងពងទាប្រៃ ជូនដល់វីរកងទ័ពជួរមុខ ទិសសមរភូមិខេត្តបន្ទាយមានជ័យ នាថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២៥។

❈លោកជំទាវ **ឃួន ឃុនឌី** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញ៖

-ជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំផាត់សណ្តាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៥។



-រៀបចំចង្ហាន់ និងបច្ច័យប្រគេនព្រះសង្ឃ ចំនួន១៦៥អង្គ ដែលកំពុងគង់នៅសិក្សារៀនសូត្រ ក្នុងវត្តឥន្ទ្រីយ៍សំ ហៅវត្តកំពង់ធំ ដើម្បីឧទ្ទិសកុសលជូនដល់បុព្វការីជន ដែលបានលាចាកទៅកាន់លោកខាងមុខក៏ដូចជាវិញ្ញាណក្ខន្ធវីរកងទ័ពដែលបានពលីជីវិតដើម្បីការពារបូរណភាពដែនដី នៅភូមិក្តី សង្កាត់ព្រៃតាហ៊ូ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ នាព្រឹកថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៥។



-គោរពវិញ្ញាណក្ខន្ធសព លោក **សឿ ម៉ុម** សមាជិកក្រុមប្រឹក្សាឃុំចើងដើង នៅភូមិពងទឹក ឃុំចើងដើង ស្រុកបារាយណ៍ ខេត្តកំពង់ធំ នារសៀលថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៥។



-គោរពវិញ្ញាណក្ខន្ធសព លោកព្រឹន្ទបាលឯក **ញឹម សុផ័ក្រ** វីរកងទ័ពឈរជើងនៅតំបន់តាថាវ និងលោកព្រឹន្ទ-បាលទោ **អយ ម៉េងស្រ៊ាន់** វីរកងទ័ពឈរជើងនៅចំណុចពាក់ស្នែក ខេត្តព្រះវិហារ បានពលីជីវិតនៅសមរភូមិ នៅស្រុកប្រាសាទសំបូរ និងស្រុកសន្ទុក ខេត្តកំពង់ធំ នាថ្ងៃទី៩ និងថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៥។

❈នាព្រឹកថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **ទឹម ផន** លេខាធិការគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគារនិងសមិទ្ធផលនានា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចក្រឡាហោម **ស ខេង** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅភូមិត្រពាំងក្រាញ់ ឃុំព្រាល ស្រុកកញ្ជៀច ខេត្តព្រៃវែង។



❈នាយប់ថ្ងៃទី២២ និងព្រឹកថ្ងៃទី២៣-២៥ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលនិងសួរសុខទុក្ខប្រជាពលរដ្ឋ នៅក្នុងភូមិ៤ សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ព្រមទាំងចូលរួមរំលែកមរណទុក្ខនិងគោរពវិញ្ញាណក្ខន្ធសពប្រជាពលរដ្ឋ នៅភូមិត្រពាំងសង្កែ ឃុំត្រពាំង-សង្កែ ស្រុកទឹកឈូ ខេត្តកំពត។

❈នាថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **ញ៉ៃវ សុខ** សមាជិកគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសពនិងនាំយកថវិកាមួយចំនួនរបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ ជូនក្រុមគ្រួសារសព លោកវរសេនីយ៍ឯក **ស្វាយ សារិទ្ធ** វីរកងទ័ព ដែលបាន




ពលីជីវិតក្នុងសមរភូមិប្រយុទ្ធនឹងការឈ្លានពានរបស់ថៃ នៅភូមិបន្ទាយក្រង ឃុំអន្លង់ត្នោត ស្រុកក្រគរ ខេត្តពោធិ៍សាត់។



❈នាថ្ងៃអាទិត្យ ទី១៤ ខែធ្នូ ឆ្នាំ២០២៥ ព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ ធម្មិកោ** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភា ឯកឧត្តម **សត ណាឌី** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភា និងលោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា បានយាង/អញ្ជើញចុះសួរសុខទុក្ខ និងនាំយកអំណោយគ្រឿងឧបភោគ បរិភោគ ចែកជូនបងប្អូនជនភៀសសឹកមកស្នាក់នៅវត្តប្រាសាទគោលវង្សី និងវត្តបទុម-វង្សី (វត្តបត់) សរុបចំនួន៣២៥គ្រួសារ នៅស្រុកអង្គរជុំ ខេត្តសៀមរាប។



❈នារសៀលថ្ងៃពុធ ទី៣ ខែធ្នូ ឆ្នាំ២០២៥ លោកជំទាវ **ភង សៅរ៍ធន** សមាជិកាគណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលនិងសួរសុខទុក្ខកម្មករ

ព្រមទាំងពិនិត្យវឌ្ឍនភាពនៃការជីកស្តារស្រះទឹកទន្លេនាម ដែលមានបណ្តោយ២១០ម៉ែត្រ ទទឹង១៨០ម៉ែត្រ ជម្រៅ ៧ម៉ែត្រ នៅឃុំចំប៉ី ស្រុកអង្គរជ័យ ខេត្តកំពត។

❈នាថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **សត ណាឌី** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភា បានអញ្ជើញជាកិត្តិយស ក្នុងពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤៧ ទិវាកំណើតរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា ២ ធ្នូ ឆ្នាំ១៩៧៨-២ ធ្នូ ឆ្នាំ២០២៥ ក្រោមអធិបតីភាពឯកឧត្តម **សៀង ណាំ** តំណាងរាស្ត្រមណ្ឌលខេត្តសៀមរាប នៅខេត្តសៀមរាប។

❈នាថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **សាយ ប៊ូរិន** សមាជិកគណៈកម្មការទី៥ព្រឹទ្ធសភា និងឯកឧត្តម **អ៊ឹង លាងហ៊ី** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញអមដំណើរសម្តេចមហាមន្ត្រី **គុយ សុផល** ឧបនាយក-រដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ចូលរួមក្នុងពិធីសំណេះសំណាល និងនាំយកអំណោយជូនគ្រួសារកងទ័ពសមរភូមិមុខ ពលរដ្ឋភៀសសឹក និងពលរដ្ឋមានជីវភាពខ្វះខាត ចំនួន១៥០គ្រួសារ មកពីឃុំទាំង៥ ក្នុងស្រុកជលគិរី នៅសាលាស្រុកជលគិរី ខេត្តកំពង់ឆ្នាំង។

❈ឯកឧត្តមបណ្ឌិត **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញ៖

-ចុះសួរសុខទុក្ខបណ្តាស្រុកដែលជាប់ព្រំដែន អំពី



សភាពការណ៍ឈ្លានពានរបស់ថៃ និងផែនការត្រូវជម្លៀសប្រជាពលរដ្ឋទៅកាន់ទីសុវត្ថិភាព នៅស្រុកសំឡូត ខេត្តបាត់ដំបង នាថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៥។

-អមដំណើរសម្តេចក្រឡាហោម **ស ខេង** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះសួរសុខទុក្ខបងប្អូនភៀសសឹក មកពីស្រុកកំរៀង ស្រុកភ្នំព្រឹក និង



ស្រុកសំពៅលូន មកស្នាក់នៅតាមបណ្តាវត្តអារាម នៃស្រុកបវេល ខេត្តបាត់ដំបង សរុបចំនួន៤.៩០០គ្រួសារ នាថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៥។

❈លោកជំទាវ **មុំ សណ្តាប់** សមាជិកាគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញ៖



-ជួបសំណេះសំណាល និងនាំយកអំណោយរបស់ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភាជូនប្រធានភូមិ អនុប្រធានភូមិ សមាជិកភូមិ ក្នុងសង្កាត់ផ្សារដើមថ្កូវ រាជធានីភ្នំពេញ នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៥។



-ជាអធិបតីក្នុងកិច្ចប្រជុំផ្ទៃក្នុងរបស់គណៈកម្មការសាខាសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍រាជធានី-ភ្នំពេញ តាមបណ្តាខណ្ឌទាំង១៤ ដែលមានសមាសភាព នៅសង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ នាថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៥។

-ចូលរួមប្រគល់ថវិកា និងសម្ភារៈ ដែលបានពីការចូលរួម



បរិច្ចាគរបស់បងប្អូននារី ជូនដល់សមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ រួមមាន៖ អង្ករ៤បេ ទឹកបរិសុទ្ធ២០កេស ទឹកត្រី២០យួរ ទឹកស៊ីអ៊ីវ២០យួរ និងថវិកាមួយចំនួន នៅទីស្នាក់ការសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ រាជធានីភ្នំពេញ នាថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៥។

❈ឯកឧត្តម **អ៊ឹង លាងហ៊ួ** សមាជិកគណៈកម្មការទី៧ ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមពិធីប្រកាសសមាសភាពក្រុមការងារមូលដ្ឋាន ខេត្ត ក្រុង ស្រុក ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន** ទេសរដ្ឋមន្ត្រី នៅសាលាខេត្តកំពង់ឆ្នាំង នាថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៥។



-ចូលរួមជាមួយសាខាកាកបាទក្រហមខេត្តក្នុងពិធីទិវាពិភពលោកកាកបាទក្រហមអឌ្ឍចន្ទក្រហម ៨ ឧសភា ឆ្នាំ២០២៥ ខួបលើកទី១៦២ ក្រោមប្រធានបទ «រួមគ្នាស្ម័គ្រចិត្ត ដើម្បីសហគមន៍មានសុខភាពល្អនិងមានភាពធន់នឹងអាកាសធាតុ» នៅឃុំក្រាំងលាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង នាថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៥។

-ចូលរួមជាមួយក្រុមប្រឹក្សាស្រុក អភិបាលស្រុក ប្រធានឃុំ មន្ត្រីសាលាស្រុក គោរពវិញ្ញាណក្ខន្ធលោកអនុសេនីយ៍ទោ **គង់ ចាន់ថាសនា** វីរយុទ្ធជនដែលបានពលីជីវិតលើសមរភូមិប្រយុទ្ធជាមួយនឹងការឈ្លានពានរបស់ថៃ នៅភូមិ



កែងតាសុក ឃុំកំពង់ហៅ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង នាថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៥។



-ចូលរួមក្នុងពិធីសំណេះសំណាលជាមួយក្រុមការងារមូលដ្ឋានឃុំទាំង៥ ស្រុកជលគិរី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចមហាមន្ត្រី **គុយ សុផល** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង នៅសាលាខេត្តកំពង់ឆ្នាំង នាថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៥។



-នាំយកថវិកា និងសាររំលែកទុក្ខរបស់រាជរដ្ឋាភិបាល ទៅប្រគល់ជូនក្រុមគ្រួសារសពលោកអនុសេនីយ៍ទោ **គង់ ចាន់ថាសនា** និងលោកអនុសេនីយ៍ទោ **ហៃ ហ៊ីម** វីរយុទ្ធជនដែលពលីជីវិតនៅសមរភូមិប្រយុទ្ធជាមួយនឹងការឈ្លានពានរបស់ថៃ នៅភូមិត្របែក ឃុំត្រងិល ស្រុកកំពង់លែង ព្រមទាំងអញ្ជើញគោរពវិញ្ញាណក្ខន្ធសព លោកអនុសេនីយ៍ទោ **ស៊ុយ គឹមយាន** នាយរងអនុសេនាតូចលេខ៣ កងកាំភ្លើងធំ កងពលតូចលេខ៤២ យោធភូមិភាគ៤

ដែលបានពលីជីវិតនៅសមរភូមិ នៅភូមិព្រៃពួច ឃុំតាំង-ក្រសាំង ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង នាថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៥។

❈លោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញ៖

-គោរពវិញ្ញាណក្ខន្ធ លោក **ហ៊ាត ចន** ដែលបានពលីជីវិតក្នុងសមរភូមិប្រយុទ្ធជាមួយការឈ្លានពានរបស់ថៃ នៅស្រុកប្រាសាទបាគង ខេត្តសៀមរាប នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៥។

-នាំយកទេយ្យទាន និងបច្ច័យមួយចំនួនវេរប្រគេនព្រះសង្ឃដើម្បីកសាងវត្តគោកធ្លក នៅខេត្តសៀមរាប នាព្រឹកថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៥។

-ចុះសួរសុខទុក្ខឧបាសិកា **ឯម រ៉េត** ប្រជាពលរដ្ឋរស់នៅស្រុកមុខកំពូល ខេត្តកណ្ដាល ដែលកំពុងសម្រាកព្យាបាលជំងឺនៅគេហដ្ឋាន នាព្រឹកថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៥។

-នាំយកទេយ្យទាន និងបច្ច័យមួយចំនួនវេរប្រគេនព្រះសង្ឃនៅវត្តស្វាយធំ វត្តស្វាយរមៀត វត្តព្រះឥន្ទកោសីយ៍ វត្តព្រះ-ឥន្ទកោសា និងវត្តគោកធ្លក នៅខេត្តសៀមរាប នាថ្ងៃទី៧ និងទី១៣ ខែធ្នូ ឆ្នាំ២០២៥។

-ចុះសួរសុខទុក្ខឧបាសិកា **ចាន់ សុវណ្ណ** ប្រជាពលរដ្ឋរស់នៅសង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ដែលកំពុងសម្រាកព្យាបាលជំងឺនៅគេហដ្ឋាន និងបានឧបត្ថម្ភថវិកាមួយចំនួន នារសៀលថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៥។

## សមាជិក សមាជិកាព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស



❈ចាប់ពីថ្ងៃទី២ ដល់ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **ខី ច័ន្ទផល** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការអេចិន្ត្រៃយ៍ ស្តីពីកិច្ចការនយោបាយ នៃសភាតំបន់អាស៊ី (APA) នៅទីក្រុងម៉ាសាដ ប្រទេសអ៊ីរ៉ង់។

❈ចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **នាង ផាត** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា បានអមដំណើរសម្តេចពិជ័យសេនា **ទៀ បាញ់** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញបំពេញទស្សនកិច្ចនៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជា-មានិតឡាវ។




❈ចាប់ថ្ងៃទី១៩ ដល់ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៥ លោកជំទាវបណ្ឌិត **ចាន់ សុខ្ខាវី** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញចូលរួម «វេទិកាកិច្ចសហប្រតិ-បត្តិការច្បាប់ចិន-អាស៊ាន លើកទី៧» នៅទីក្រុងធុងឈីង នៃសាធារណរដ្ឋប្រជាមានិតចិន។

# សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២៥ សមាជិកព្រឹទ្ធសភា ចំនួន៨រូប បានអញ្ជើញចូលរួមជាគណៈអធិបតីនិងជាកិត្តិយសក្នុងពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤៧ ទិវាកំណើតរណសិរ្សសាមគ្គី អភិវឌ្ឍន៍មាតុភូមិកម្ពុជា នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ។



❈នាថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **យស ផានីត្តា** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសព លោកស្រី **សម បុប្ផា** ប្រធានការិយាល័យជំនួយការគណៈកម្មការទី៥ព្រឹទ្ធសភា នៃអគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅវត្តឧណ្ណាលោម រាជធានីភ្នំពេញ។

❈ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញ៖



-ជាអធិបតីក្នុងពិធីបើកបវេសនកាលឆ្នាំសិក្សា២០២៥-២០២៦ របស់វិទ្យាស្ថានកសិកម្ម ឧកញ៉ា **ម៉ុង ឫទ្ធី** ភូមិឫទ្ធី១ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នាព្រឹកថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៥។




-គោរពវិញ្ញាណក្ខន្ធសព ឯកឧត្តម **គីម បូរី** អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន នៅបុរីប៉េងហួត សែនសុខ រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៥។



-ជាគណៈអធិបតីក្នុងពិធីចែកអំណោយដល់ប្រជាពលរដ្ឋដែលរងគ្រោះដោយខ្យល់កន្ត្រាក់ ចំនួន២.១៩៧គ្រួសារ នៅស្រុកព្រៃនប់ ក្រោមអធិបតីភាពលោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** អនុប្រធានអចិន្ត្រៃយ៍កាកបាទក្រហមកម្ពុជា នៅភូមិវាលធំ ឃុំវាលរេញ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ នាព្រឹកថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៥។

❈ឯកឧត្តមបណ្ឌិត **ចែម វីឡា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញ៖

-ទទួលគ្រឿងឥស្សរិយយស Grand Cross of Merit with Star of the Order of Merit of the Federal Republic of Germany របស់សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ពីឯកឧត្តមប្រធានាធិបតី នៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់



តាមរយៈលោក Stefan Messerer ឯកអគ្គរដ្ឋទូតអាល្លឺម៉ង់ ប្រចាំព្រះរាជាណាចក្រកម្ពុជា នាព្រឹកថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៥។



-ចូលរួមពិធីជប់លៀងជាមិត្តភាពជូនឯកឧត្តម Stefan Messerer ឯកអគ្គរដ្ឋទូតសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ **ផែន សាវនី** អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៅភោជនីយដ្ឋាន TOPAZ ក្នុងរាជធានីភ្នំពេញ នាថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៥។

-ចូលជួបសម្ដែងការគួរសមនិងជម្រាបលា ព្រមទាំងទទួលអនុសាសន៍ពីថ្នាក់ដឹកនាំរដ្ឋសភា សម្ដេចវិបុលសេនាភក្ដី **សាយឈុំ** សម្ដេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** សម្ដេចពិជ័យសេនា **ទៀ បាញ់** សម្ដេចក្រឡាហោម **ស ខេង** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម **ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មុនចាកចេញទៅបំពេញតួនាទីជាអគ្គលេខាធិការអន្តរសភាអាស៊ានអាយប៉ា (AIPA) សម្រាប់អាណត្តិទី៧ នៅវិមានរដ្ឋសភា នាព្រឹកថ្ងៃទី៩ ទី១០ ទី១៥ និងថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៥។




❈នារសៀលថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ចែម វីឌ្យា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានដឹកនាំគណៈប្រតិភូគណៈកម្មការទី៥ និងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ អញ្ជើញគោរពវិញ្ញាណក្ខន្ធសព លោកស្រី **សម បុប្ផា** ប្រធានការិយាល័យជំនួយការគណៈកម្មការទី៥ នៃអគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅវត្តឧណ្ណាលោម សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

❈នាថ្ងៃពុធ ទី១៧ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ចែម វីឌ្យា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា និងឯកឧត្តម **ខៃ៉ត ចន្ថាវី** សមាជិកគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញចូលរួមដង្ហែនិងជូនភ្លើងបូជាសព លោកស្រី **សម បុប្ផា** ប្រធានការិយាល័យជំនួយការគណៈកម្មការទី៥ព្រឹទ្ធសភា នៃអគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅវត្តឧណ្ណាលោម សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

❈នាព្រឹកថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៥ លោកជំទាវបណ្ឌិត **ចាន់ សុទ្ធាវី** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា និងឯកឧត្តម **អ៊ុំ សារឹទ្ធ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំអន្តរគណៈកម្មការរដ្ឋសភា ដឹកនាំដោយឯកឧត្តម **អេង ខេង ខឡានា** ប្រធានគណៈកម្មការនីតិកម្ម និងយុត្តិធម៌ នៃរដ្ឋសភា ដើម្បីពិនិត្យពិភាក្សាលើសេចក្ដីស្នើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពី ការបោះឆ្នោត

ជ្រើសតាំងសមាជិកព្រឹទ្ធសភា នៅសាលសន្និសីទបាយ័ន នៃវិមានរដ្ឋសភា។

❈គណៈកម្មការទី៨ និងក្រុមសមាជិកាព្រឹទ្ធសភា ដឹកនាំដោយលោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការ និងជាប្រធានក្រុម បានអញ្ជើញ៖



-អមដំណើរសម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះសួរសុខទុក្ខ និងនាំយកអំណោយជាគ្រឿងឧបភោគ បរិភោគ សម្ភារៈ និងថវិកាផ្តល់ជូនគ្រួសារកងទ័ពជួរមុខ ចំនួន៨៩៩គ្រួសារ នៅភូមិសែនរុងរឿង១ ឃុំទឹកក្រហម ស្រុកជាំក្សាន្ត និងកងពលតូចអន្តរាគមន៍លេខ៩ កងពលធំអន្តរាគមន៍លេខ៣ ទិសទី១ (មុំបី) ប្រាសាទព្រះវិហារ នៅខេត្តព្រះវិហារ នាព្រឹកថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២៥។



-ដឹកនាំក្រុមសមាជិកាព្រឹទ្ធសភា ចូលរួមគោរពវិញ្ញាណក្ខន្ធសព លោកអនុសេនីយ៍ត្រី **ហៃន គីណា** វីរកងទ័ពវរសេនាតូចកងពលលេខ៣៩៤ កងពលតូចអន្តរាគមន៍លេខ៩ កងពលធំអន្តរាគមន៍លេខ៣ ទិសប្រាសាទព្រះវិហារ នៅភូមិបឹងកេតលើ ឃុំព្រៃកកក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម នារសៀលថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៥។



-នាំយកគ្រឿងឧបភោគ បរិភោគ សម្ភារៈ និងថវិកាឧបត្ថម្ភជូនវីរកងទ័ពឈរជើងនៅខេត្តពោធិ៍សាត់ ដែលកំពុងប្រយុទ្ធការពារបូរណភាពទឹកដី នៅសាលាស្រុកវាលវែង ខេត្តពោធិ៍សាត់ នារសៀលថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៥។

-ដាល់អំបុកជូនវីរកងទ័ព វីរនគរបាលជាតិ ដែលកំពុងឈរជើងបំពេញបេសកកម្មយ៉ាងអង់អាចក្លាហានការពារដែនអធិបតេយ្យភាពនិងបូរណភាពទឹកដីរបស់កម្ពុជា នៅភូមិស្វាយចេក ឃុំស្វាយជ្រុំ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង នាព្រឹកថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៥។



-គោរពវិញ្ញាណក្ខន្ធសព លោកអនុសេនីយ៍ទោ **គង់ចាន់ថាសនា** វីរយុទ្ធជនបម្រើការនៅកងពលតូចថ្មើរជើងលេខ៤២ ឈរជើងនៅតំបន់ទិសប្រាសាទតាមាន់ ខេត្តឧត្តរមានជ័យ ដែលបានពលីជីវិតក្នុងសមរភូមិប្រយុទ្ធជាមួយទាហានឈ្លានពានរបស់ថៃ នៅឃុំកំពង់ហាវ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង នារសៀលថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៥។

❈នាថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៥ លោកជំទាវ **មាន សំអាន** ប្រធាន និងលោកជំទាវ **ឃួន ឃុនឌី** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញជាគណៈអធិបតីក្នុងពិធីប្រកាសទទួលស្គាល់ការកែសម្រួលនិងបំពេញបន្ថែមសមាស-



ភាពគណៈកម្មការសាខាសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ខេត្តកំពង់ធំ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅសាលាខេត្តកំពង់ធំ។

❈ឯកឧត្តម **ឈួន ឆាម** អនុប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញ៖

-ជាគណៈអធិបតីក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារបរិស្ថានឆ្នាំ២០២៥និងលើកទិសដៅការងារឆ្នាំ២០២៦ ក្រោមអធិបតីភាពឯកឧត្តមសន្តិបណ្ឌិត **នេត សាវឿន** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅទីស្តីការក្រសួងបរិស្ថាន នារសៀលថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៥។

-ចូលរួមក្នុងទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៥ ក្រោមអធិបតីភាពឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៌កោះពេជ្រ នារសៀលថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៥។



❈នាព្រឹកថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **ប៉ុល លឹម** អនុប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា បានអញ្ជើញជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការច្រកទ្វារព្រំដែនអន្តរជាតិម៉ឺនជ័យ (ខេត្តព្រៃវែង) តឹនណាម (ខេត្តតៃនិញ) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម **ផាម មិញជីញ** (Pham Minh Chinh) នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅភូមិម៉ឺនជ័យ ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង។

❈លោកជំទាវបណ្ឌិត **អ៊ុក ម៉ាលី** សមាជិកាគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញ៖



-ជាតំណាងដ៏ខ្ពង់ខ្ពស់សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា ទទួលព្រះរាជទ្រព្យដ៏ឧត្តុង្គឧត្តមពីសម្តេចមហាមន្ត្រី **គុយ សុផល** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ដែលព្រះអង្គសព្វព្រះរាជហឫទ័យប្រោសព្រះរាជទាននូវព្រះរាជទ្រព្យចំនួន១០ម៉ឺនដុល្លារ ជូនកាកបាទក្រហមកម្ពុជា ដើម្បីជួយដល់ប្រជារាស្ត្រភៀសសឹកនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ នៅទីស្តីការក្រសួងព្រះបរមរាជវាំង នារសៀលថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៥។

-អមដំណើរសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន**



ប្រធានកាកបាទក្រហមកម្ពុជា ចុះសួរសុខទុក្ខនិងនាំយកអំណោយមនុស្សធម៌ផ្តល់ជូនវីរយុទ្ធជនរងរបួសក្នុងសមរភូមិការពារបូរណភាពទឹកដី ដែលកំពុងសម្រាកព្យាបាល នៅតាមមន្ទីរពេទ្យ ក្នុងរាជធានីភ្នំពេញ នាថ្ងៃទី១៥ និងថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៥។



-អមដំណើរសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា អញ្ជើញរៀបចំសម្ភារៈនិងអំណោយមនុស្សធម៌សម្រាប់ផ្តល់ជូនជនភៀសសឹក និងវីរកងទ័ពកម្ពុជា នាល្ងាចថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៥ នៅរាជធានីភ្នំពេញ។

❈លោកជំទាវ **ចឹក ហេង** សមាជិកាគណៈកម្មការទី៤ ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមក្នុងកិច្ចប្រជុំបូកសរុបសមិទ្ធផលការងារប្រចាំ



ឆ្នាំ២០២៥ និងទិសដៅការងារអាទិភាពជាយុទ្ធសាស្ត្រឆ្នាំ២០២៦ របស់កាកបាទក្រហមកម្ពុជា ក្រោមអធិបតីភាពលោកជំទាវ **ពុំ ចន្ទីនី** អគ្គលេខាធិការកាកបាទក្រហមកម្ពុជា នៅទីស្នាក់ការកណ្តាលកាកបាទក្រហមកម្ពុជា នាព្រឹកថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៥។

-ជាកិត្តិយសក្នុងពិធីបិទកិច្ចប្រជុំបូកសរុបសមិទ្ធផល



ការងារប្រចាំឆ្នាំ២០២៥ និងលើកទិសដៅការងារអាទិភាពជាយុទ្ធសាស្ត្រឆ្នាំ២០២៦ របស់កាកបាទក្រហមកម្ពុជា ក្រោមអធិបតីភាពលោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត** អនុប្រធានអចិន្ត្រៃយ៍ នៅទីស្នាក់ការកណ្តាលកាកបាទក្រហមកម្ពុជា នាថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៥។

❈ឯកឧត្តម **ខ៉ែត ចន្ថាវី** សមាជិកគណៈកម្មការទី៥ ព្រឹទ្ធសភា បានអញ្ជើញ៖

-គោរពវិញ្ញាណក្ខន្ធសពនិងចូលរួមក្នុងពិធីហែសពឯកឧត្តមឧត្តមសេនីយ៍ទោ **ផូ ខន** ទីប្រឹក្សាក្រសួងមហាផ្ទៃ និងអតីតជាប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់ នៃអគ្គស្នងការនគរបាលជាតិ នៅព្រែកហូរ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល នាល្ងាចថ្ងៃទី២៩ ខែវិច្ឆិកា និងថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២៥។



❈នាថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **អ៊ឹង លាងឆ្វី** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីបើកសិក្ខាសាលាស្តីពី កិច្ចសន្ទនាអន្តរជំនឿសាសនា ដើម្បីសុខដុមនីយកម្មសាសនានៅកម្ពុជាឆ្នាំ២០២៥ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **ចាយ បូរិន** រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា នៅទីស្តីការក្រសួងធម្មការ និងសាសនា៕

# ឯកឧត្តម ឡាយ សំកុល អញ្ជើញជាគណៈអធិបតីក្នុងពិធី បិទសិក្ខាសាលាស្ដីពី «កិច្ចការសភា»

នារសៀលថ្ងៃព្រហស្បតិ៍ ទី១៨ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា និងឯកឧត្តមបណ្ឌិត **កែវ ពិសិដ្ឋ** នាយកខុទ្ទកាល័យ**សម្តេចមហារដ្ឋសភាធិការធិបតីប្រធានរដ្ឋសភា** និងជាអគ្គលេខាធិការរងរដ្ឋសភាប្រចាំការ បានអញ្ជើញជាគណៈអធិបតីក្នុងពិធីបិទសិក្ខាសាលាស្ដីអំពី «កិច្ចការសភា» ដែលសហការរៀបចំដោយរដ្ឋសភានិងព្រឹទ្ធសភា នៃសាធារណរដ្ឋបារាំង ក្រោមក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការសមាគមសភានិយាយភាសាបារាំង (APF) និងមជ្ឈមណ្ឌលសភាអាស៊ី (PCAsia) ចំនួនពីរថ្ងៃ នៅថ្ងៃ១៧-១៨ ខែធ្នូ ឆ្នាំ២០២៥ នៅវិមានរដ្ឋសភា និងតាមប្រព័ន្ធនិម្មិត។




*ឯកឧត្តម ឡាយ សំកុល និងឯកឧត្តមបណ្ឌិត កែវ ពិសិដ្ឋ អញ្ជើញជាគណៈអធិបតីក្នុងពិធីបិទសិក្ខាសាលា*

នៅក្នុងឱកាសនោះ **ឯកឧត្តមអគ្គលេខាធិការ** បានអបអរសាទរនិងវាយតម្លៃខ្ពស់ចំពោះលទ្ធផលប្រកបដោយផ្លែផ្កានៃអង្គសិក្ខាសាលា ជាពិសេសថ្លែងអំណរគុណ ចំពោះការចូលរួមចំណែកយ៉ាងសកម្មរបស់វាគ្មិនគន្លឹះនិងសិក្ខាកាម ដែលជាមន្ត្រីជំនាញសភា មកពីសភា កម្ពុជា បារាំង ព្រុយណេ ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន ថៃ និងឡាវ នៅក្នុងកិច្ចពិភាក្សានិងការផ្លាស់ប្តូរបទពិសោធ។ សិក្ខាសាលាតំបន់នេះពិតជាបានផ្តល់នូវកាលានុវត្តភាពដ៏ល្អប្រពៃសម្រាប់សិក្ខាកាមទាំងអស់ មិនគ្រាន់តែបានឈ្វេងយល់ពីគ្នាទៅវិញទៅមកនូវការអនុវត្តជាក់ស្តែងរបស់សភាតាមប្រទេសនីមួយៗ ដូចជានីតិវិធីនីតិកម្ម ការងារគណៈកម្មការជំនាញ និងឧបករណ៍ត្រួតពិនិត្យការអនុវត្តច្បាប់ ក្នុងលក្ខណៈប្រៀបធៀប និងការអនុវត្តជាក់ស្តែង។ សិក្ខាសាលានេះ ក៏ជាវេទិកាមួយសម្រាប់ការពង្រឹងកិច្ចសហប្រតិបត្តិការក្របខ័ណ្ឌអន្តរសភាតំបន់និងការធ្វើអន្តរកម្មការទូតសភាឱ្យកាន់តែស៊ីជម្រៅថែមទៀត ដើម្បីរួមវិភាគទានដល់ការអភិវឌ្ឍធនធានមនុស្សនិងស្ថាប័នសភាតំបន់ផងដែរ។

ក្នុងឱកាសនោះផងដែរ **ឯកឧត្តមអគ្គលេខាធិការ**ក៏បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ជូនចំពោះសភា នៃសាធារណរដ្ឋបារាំង សមាគមសភាប្រើភាសាបារាំង (APF) និងមជ្ឈមណ្ឌលសភាអាស៊ី (PCAsia) ដែលកន្លងមកតែងតែយកចិត្តទុកដាក់ខ្ពស់ ផ្តល់ការគាំទ្រ និងការរួមចំណែកដល់ការពង្រឹងសមត្ថភាពមន្ត្រីជំនាញសភានិងអភិវឌ្ឍវិជ្ជាជីវៈសភាតំបន់ផងដែរ ជាពិសេសថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ជូនចំពោះរដ្ឋសភាកម្ពុជា ដែលបានសហការរៀបចំសិក្ខាសាលា បានយ៉ាងល្អប្រសើរ។



*ឯកឧត្តម ឡាយ សំកុល អញ្ជើញមានប្រសាសន៍បិទអង្គសិក្ខាសាលា*

ឆ្លៀតក្នុងឱកាសនោះ **ឯកឧត្តមអគ្គលេខាធិការ**បានជម្រាបជូនអង្គសិក្ខាសាលាជ្រាបអំពីបច្ចុប្បន្នភាពនៃការវិវត្តថ្មីៗនៃជម្លោះព្រំដែនកម្ពុជា-ថៃ ដែលបានបង្កវិនាសកម្ម





យ៉ាងធំធេងចំពោះកម្ពុជា ជាពិសេសប្រជាពលរដ្ឋរស់នៅតាមបណ្តោយព្រំដែន រួមមានកុមារ ស្ត្រីពពោះ និងចាស់ជរាដែលកំពុងត្រូវបានបង្ខំឱ្យផ្លាស់ទីលំនៅដោយសារសង្គ្រាម និងការវាយប្រហារឈ្លានពានពីកងទ័ពថៃ។

ជាចុងបញ្ចប់ **ឯកឧត្តមអគ្គលេខាធិការ**សង្ឃឹមថា ស្ថាប័ននៃសភាជាសមាជិកនឹងបន្តពង្រឹងកិច្ចសហប្រតិបត្តិការដែលជាផលប្រយោជន៍រួម និងជូនពរឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ព្រឹទ្ធសភា វាគ្មិនគន្លឹះ បុគ្គលិកនៃមជ្ឈមណ្ឌលសភាអាស៊ី និងសិក្ខាកាមទាំងអស់ សូមមានសុខភាពល្អបរិបូរណ៍ និងទទួលបានជោគជ័យគ្រប់ភារកិច្ច៕



*ទិដ្ឋភាពក្នុងពិធីបិទសិក្ខាសាលា*



*ទិដ្ឋភាពថតរូបអនុស្សាវរីយ៍ក្នុងពិធីបិទអង្គសិក្ខាសាលា*

ខ្លឹមសារ៖ ខុទ្ទកាល័យឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា

រូបភាព៖ នាយកដ្ឋានព័ត៌មាន

# ឯកឧត្តម ឡាយ សំកុល អញ្ជើញដឹកនាំកិច្ចប្រជុំ បូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែវិច្ឆិកា និងកំណត់ទិសដៅការងារខែធ្នូ ឆ្នាំ២០២៥



*ឯកឧត្តម ឡាយ សំកុល អគ្គលេខាធិការព្រឹទ្ធសភា (រូបទី២ពីឆ្វេង) និងឯកឧត្តមអគ្គលេខាធិការរងព្រឹទ្ធសភា អញ្ជើញក្រោកឈរស្មឹងស្មាធិ៍គោរពវិញ្ញាណក្ខន្ធវីរយុទ្ធជន*

នាព្រឹកថ្ងៃសុក្រ ទី១៩ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែវិច្ឆិកានិងកំណត់ទិសដៅការងារខែធ្នូ ឆ្នាំ២០២៥ ដោយមានការអញ្ជើញចូលរួមពីតំណាងខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដែលមានឋានៈចាប់ពីប្រធាននាយកដ្ឋានឡើង នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។

មុននឹងចាប់ផ្តើមដំណើរការអង្គប្រជុំ **ឯកឧត្តមអគ្គលេខាធិការ** បានស្នើដល់អ្នកចូលរួមក្នុងកិច្ចប្រជុំទាំងអស់ ក្រោកឈរស្មឹងស្មាធិ៍ ដើម្បីគោរពវិញ្ញាណក្ខន្ធវីរយុទ្ធជនយើង ដែលបានពលីជីវិតក្នុងសមរភូមិប្រយុទ្ធជាមួយការឈ្លានពានរបស់កងទ័ពថៃ។

បន្ទាប់ពីបានទស្សនាវីដេអូបូកសរុបលទ្ធផលការងារប្រចាំខែវិច្ឆិកានិងទិសដៅការងារខែធ្នូ ឆ្នាំ២០២៥រួចមក **ឯកឧត្តមអគ្គលេខាធិការ** បានជម្រាបជូនអង្គប្រជុំអំពីសភាពការណ៍វិវត្តន៍ថ្មីៗ នៅតាមបណ្តោយព្រំដែនរវាងកម្ពុជា-ថៃ និងបានលើកឡើងអំពីវីរភាពអង់អាចក្លាហានរបស់វីរកងកម្លាំងប្រដាប់អាវុធយើង ព្រមទាំងការរួមចំណែកដ៏ធំធេងរបស់សម្តេចតេជោ **ហ៊ុន សែន** ជាមួយរាជរដ្ឋាភិបាល ក្នុងការការពារបូរណភាពទឹកដីនិងអធិបតេយ្យជាតិ ពីការឈ្លានពានរបស់កងទ័ពថៃ។ ទន្ទឹមនឹងនេះ ឯកឧត្តម បានថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ ដែលបានចូលរួមថវិកា តាមរយៈមូលនិធិរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជូនដល់វីរកងកម្លាំងប្រដាប់អាវុធនិងប្រជាជនភៀសសឹក។

ទន្ទឹមនឹងនោះ **ឯកឧត្តមអគ្គលេខាធិការ** បានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ ដែលបានរួមចំណែកសម្រេចបាននូវសមិទ្ធផលជាច្រើន ក្នុងរយៈពេល១២ខែ នៃឆ្នាំ២០២៥ និងណែនាំឱ្យរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំឆ្នាំ២០២៥ ព្រមទាំងត្រៀមផ្តល់សេវាលើមុខងារនីតិកម្ម ដោយត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍និងប្រជុំពេញអង្គព្រឹទ្ធសភា ដើម្បីពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងនិងសេចក្តីស្នើច្បាប់ និងការបោះឆ្នោតជ្រើសតាំងសមាជិកគណៈកម្មការទី៥ព្រឹទ្ធសភា។ បន្ថែមពីនេះ ឯកឧត្តមក៏បានរំលេចអំពីគំនិតផ្តួចផ្តើមរបស់**ឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា** ឱ្យមានក្រុមសិក្សាស្រាវជ្រាវអំពីការកសាងខឿនប្រជាជនការពារ នៅតាមបណ្តោយព្រំដែនជាមួយប្រទេសជិតខាង។

ចំពោះការអភិវឌ្ឍស្ថាប័ន **ឯកឧត្តមអគ្គលេខាធិការ** បានជម្រាបអំពីកម្មវិធីសម្ពោធអគារថ្មី នៃព្រឹទ្ធសភានិងការរៀបចំសៀវភៅស្ថាបត្យកម្មអគារព្រឹទ្ធសភា ព្រមទាំងណែនាំដល់ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានស្រាវជ្រាវ និងនាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស សហការជាមួយមជ្ឈមណ្ឌលស្រាវជ្រាវច្បាប់ចិន-អាស៊ាន នៃសាធារណរដ្ឋប្រជាមានិតចិន ដើម្បីសម្របសម្រួលលើការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា ដែលបានចុះហត្ថលេខាកាលពីពេលថ្មីៗនេះ សម្រាប់ជាប្រយោជន៍ជូនដល់មន្ត្រី និងស្ថាប័ន។ ជាមួយគ្នានេះ ឯកឧត្តមក៏បានណែនាំអគ្គនាយកដ្ឋានព័ត៌មាននិងទំនាក់ទំនងសាធារណៈរៀបចំគេហទំព័រព្រឹទ្ធសភាថ្មី សម្រាប់ជាកន្លែងផ្តល់និងតាមដានព័ត៌មានពីគ្រប់មជ្ឈដ្ឋាន និងត្រៀមដំណើរការមុនសម្ពោធអគារថ្មី និងត្រៀមរៀបចំផ្លាស់ប្តូរបញ្ចូរតាំងពិព័រណ៍រូបភាពនៅខ្លោងទ្វារចូលខាងមុខព្រឹទ្ធសភា ទៅជាផ្ទាំងវីដេអូឌីជីថល។ បន្ថែមពីនេះ ឯកឧត្តមក៏បានលើកឡើងអំពីការរៀបចំបែបបទនីតិវិធីនៃការផ្ទេរមន្ត្រីពីអង្គភាពមួយទៅអង្គភាពមួយ ឱ្យត្រឹមត្រូវនិងមានប្រសិទ្ធភាពនាពេលខាងមុខ និងការរៀបចំចងក្រងបោះពុម្ពសៀវភៅស្តីពី ការអនុម័តច្បាប់ សេចក្តីសម្រេចនានា ឯកសារគតិយុត្តរបស់ស្ថាប័ន។



*ឯកឧត្តម ឡាយ សំកុល អញ្ជើញមានប្រសាសន៍ក្នុងកិច្ចប្រជុំបូកសរុប*

ជាចុងបញ្ចប់ **ឯកឧត្តមអគ្គលេខាធិការ** បានណែនាំដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ បន្តខិតខំយកចិត្តទុកដាក់ខ្ពស់ក្នុងការផ្តល់សេវាឱ្យបានទាន់ពេលវេលា និងគ្រប់ជ្រុងជ្រោយជូនស្ថាប័ន ព្រមទាំងជូនពរសូមឱ្យធ្វើដំណើរប្រកបដោយសុខសុវត្ថិភាព ក្នុងឱកាសពិធីបុណ្យចូលឆ្នាំសកល២០២៦ នាពេលខាងមុខនេះ៕







*ទិដ្ឋភាពក្នុងពិធីប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែវិច្ឆិកា និងកំណត់ទិសដៅការងារខែធ្នូ ឆ្នាំ២០២៥*

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន

# ឯកឧត្តម ខេង សិទ្ធិគុណា អញ្ជើញជាគណៈអធិបតីក្នុងពិធីធ្វើបាឋកថា ស្តីពី អភិបាលកិច្ចឌីជីថល

នាព្រឹកថ្ងៃពុធ ទី២៤ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **ខេង សិទ្ធិគុណា** អគ្គលេខាធិការរងព្រឹទ្ធសភា តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភានិងឯកឧត្តម **កែវ សុទ្ធិ** រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានអញ្ជើញជាគណៈអធិបតីក្នុងពិធីធ្វើបាឋកថាស្តីពី អភិបាលកិច្ចឌីជីថល នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សរុបចំនួន៨៣នាក់។



ឯកឧត្តម កែវ សុទ្ធិ និងឯកឧត្តម ខេង សិទ្ធិគុណា

មុននឹងចាប់ផ្តើមដំណើរការអង្គពិធី អ្នកចូលរួមទាំងអស់បានក្រោកឈរគោរពទង់ជាតិនិងស្មិងស្មាធិ៍ ដើម្បីគោរពវិញ្ញាណក្ខន្ធវីរយុទ្ធជន ដែលបានពលីជីវិតក្នុងសមរភូមិប្រយុទ្ធជាមួយការឈ្លានពានរបស់កងទ័ពថៃ។

ក្នុងឱកាសនោះ **ឯកឧត្តមអគ្គលេខាធិការរង** បានគូសបញ្ជាក់ថា បាឋកថាស្តីពីអភិបាលកិច្ចឌីជីថល គឺជាប្រធានបទដ៏មានសារៈសំខាន់ និងទាន់សម័យកាល ជាពិសេសនៅក្នុងបរិបទ ដែលប្រទេសកម្ពុជាបាននិងកំពុងបោះជំហានកាន់តែស៊ីជម្រៅចូលទៅក្នុងយុគសម័យនៃបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ ដែលទាមទារឱ្យមានការផ្លាស់ប្តូររចនាសម្ព័ន្ធពីការគ្រប់គ្រងតាមបែបប្រពៃណីមកជាការគ្រប់គ្រងតាមបែបឌីជីថលវិញ។ ក្នុងន័យនេះ អភិបាលកិច្ចឌីជីថលបានក្លាយទៅជាមូលដ្ឋានគ្រឹះដ៏សំខាន់មួយដែលមិនអាចខ្វះបាននៅក្នុងការរួមចំណែកបង្កើនប្រសិទ្ធភាពនៃរដ្ឋបាលសាធារណៈ ការបម្រើសេវាសាធារណៈ និងការអភិវឌ្ឍប្រកបដោយចីរភាព។ ដើម្បីឆ្លើយតបទៅនឹងចរន្តនៃបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ ដែលកំពុងជះឥទ្ធិពលយ៉ាងខ្លាំងមកលើសេដ្ឋកិច្ចនិងសង្គម រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវ «ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥» និង «គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥» ដែលជាផែនទីបង្ហាញផ្លូវដ៏សំខាន់ ដើម្បីជំរុញកម្ពុជាក្នុងការពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថល សំដៅសម្រេចបាននូវចក្ខុវិស័យ «ប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងចំណូលខ្ពស់នៅឆ្នាំ២០៥០»។





ឯកឧត្តម ខេង សិទ្ធិគុណា និងឯកឧត្តម កែវ សុទ្ធិ អញ្ជើញមានប្រសាសន៍ក្នុងអង្គពិធី









*ទិដ្ឋភាពក្នុងពិធីធ្វើបាឋកថាស្ដីពីអភិបាលកិច្ចឌីជីថល*

ពិធីធ្វើបាឋកថា មានគោលបំណងសំខាន់ចំនួន៣គឺ៖

**១-ពង្រីកការយល់ដឹង៖ ស្វែងយល់បន្ថែមអំពី «អភិបាលកិច្ចឌីជីថល» និងការប្រើប្រាស់បច្ចេកវិទ្យា ដើម្បីបង្កើនប្រសិទ្ធភាពការងាររដ្ឋបាលសាធារណៈនិងរបស់ស្ថាប័នព្រឹទ្ធសភា។**

**២-ផ្សព្វផ្សាយគោលនយោបាយ៖ បញ្ជ្រាបចំណេះដឹងអំពីយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការកសាងរាជរដ្ឋាភិបាលឌីជីថលដែលឆ្លាតវៃ និងមានបរិយាបន្ន។**

**៣-ការត្រៀមខ្លួន៖ បំផុសស្មារតីដល់មន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឱ្យត្រៀមលក្ខណៈសម្បត្តិ និងជំនាញឌីជីថល ដើម្បីរួមចំណែកសម្រេចឱ្យបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ និង ២០៥០។**

ក្នុងឱកាសនោះផងដែរ **ឯកឧត្តមអគ្គលេខាធិការរង** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដែលតែងតែបានគាំទ្រដល់ដំណើរការអភិវឌ្ឍស្ថាប័នព្រឹទ្ធសភា ទាំងហេដ្ឋារចនាសម្ព័ន្ធរឹង និងការអភិវឌ្ឍធនធានមនុស្ស។ ទន្ទឹមនឹងនេះឯកឧត្តមក៏បានថ្លែងអំណរគុណឯកឧត្តម **កែវ សុទ្ធិ** រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមជាវាគ្មិនកិត្តិយស ដើម្បីចែករំលែកចំណេះដឹង និងបទពិសោធនានាជុំវិញប្រធានបទ អភិបាលកិច្ចឌីជីថល ជូនដល់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

ពិធីបាឋកថានេះ ប្រព្រឹត្តទៅមានរយៈមួយព្រឹក ដោយមានការធ្វើបាឋកថាពីឯកឧត្តម **កែវ សុទ្ធិ** រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងសហការី ស្ដីពី ១-រចនាសម្ព័ន្ធក្រសួងប្រៃសណីយ៍ (មុនវិភាគមុខងារ), ២-វិស័យប្រៃសណីយ៍គាំទ្រដល់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ៣-កំណែទម្រង់និងការអភិវឌ្ឍវិស័យទូរគមនាគមន៍, ៤-វិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន, ៥-អភិបាលកិច្ចឌីជីថល, ៦-អភិបាលកិច្ចបញ្ញាសិប្បនិម្មិត៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន

# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❈នាថ្ងៃទី២៤ ខែវិច្ឆិកា ថ្ងៃទី១ និងថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា និងថ្នាក់ដឹកនាំ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងក្រុមការងារបច្ចេកទេសសាងសង់អគារ បានអញ្ជើញអមដំណើរឯកឧត្តម **ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងជាប្រធានគណៈកម្មការសាងសង់អគារថ្មី នៃព្រឹទ្ធសភា ចុះពិនិត្យមើលវឌ្ឍនភាពនៃដំណើរការសាងសង់អាគារថ្មីព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា។



❈នារសៀលថ្ងៃព្រហស្បតិ៍ ទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា និងជាសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ (ក.ជ.ប.ព.) លើកទី៤ អាណត្តិទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ប្រធាន ក.ជ.ប.ព. នៅអង្គភាពប្រឆាំងអំពើពុករលួយ។



❈នារសៀលថ្ងៃអង្គារ ទី២ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានដឹកនាំគណៈប្រតិភូអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញគោរពវិញ្ញាណក្ខន្ធសព ឧបាសិកា **សេង យុអៀន** ម្តាយបង្កើតលោក **លឹម សុនា** អភិបាលខណ្ឌជ្រោយចង្វារ នៅស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។



❈នារសៀលថ្ងៃចន្ទ ទី១៥ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា និងសហការី បានអញ្ជើញប្រជុំជាមួយនឹងថ្នាក់ដឹកនាំគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ តំណាងក្រសួងព្រះបរមរាជវាំង ដើម្បីពិនិត្យពិភាក្សាអំពីការត្រៀមរៀបចំពិធីក្រុងពាលីនិងពិធីចម្រើនព្រះបរិត្ត ព្រមទាំងការត្រៀមរៀបចំពិធីសម្ពោធអគារថ្មីព្រឹទ្ធសភា នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។



## សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❈នារសៀលថ្ងៃអង្គារ ទី១៦ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភានិងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានទទួលជួបតំណាងធនាគារអេស៊ីលីដា នាំយកថវិកាវិភាគទានរបស់ធនាគារអេស៊ីលីដា ចំនួន២០០លានរៀល ជូនដល់មូលនិធិព្រឹទ្ធសភាសម្រាប់គាំទ្រកងទ័ពជួរមុខនិងជនភៀសសឹក នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។



❈នាល្ងាចថ្ងៃអង្គារ ទី១៦ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានដឹកនាំប្រតិភូអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញគោរពវិញ្ញាណក្ខន្ធសព លោកស្រី **សម បុប្ផា** ប្រធានការិយាល័យជំនួយការគណៈកម្មការទី៥ នៃអគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅវត្តឧណ្ណាលោម រាជធានីភ្នំពេញ។



❈នារសៀលថ្ងៃអង្គារ ទី១៦ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានទទួលជួបពិភាក្សាការងារជាមួយគណៈប្រតិភូរដ្ឋសភា នៃសាធារណរដ្ឋបារាំង ដឹកនាំដោយ លោក Febrice Robert, អតីតនាយកទទួលបន្ទុកនីតិកម្មនិងត្រួតពិនិត្យព្រឹទ្ធសភាបារាំង នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។



❈នាថ្ងៃអង្គារ ទី២ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឈិច យីស៊ាន** នាយកខុទ្ទកាល័យសម្តេចតេជោ ប្រធានព្រឹទ្ធសភា និងសហការី បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសព ឧបាសិកា **សេង យុអៀន** ម្តាយបង្កើតរបស់លោក **លឹម សុនា** អភិបាលខណ្ឌជ្រោយចង្វារ នៅឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។



# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❈នារសៀលថ្ងៃសុក្រ ទី១៩ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភា រួមជាមួយថ្នាក់ដឹកនាំអគ្គនាយកដ្ឋានព័ត៌មាននិងទំនាក់ទំនងសាធារណៈ បានអញ្ជើញចុះពិនិត្យការរៀបចំបណ្ណាល័យថ្មីព្រឹទ្ធសភា ដែលស្ថិតនៅជាន់ខាងក្រោម នៃអគារថ្មីព្រឹទ្ធសភា។



❈នាថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី និងអគ្គនាយកដ្ឋានស្រាវជ្រាវ ប្រចាំខែវិច្ឆិកា និងកំណត់ទិសដៅការងារខែធ្នូ ឆ្នាំ២០២៥ នៅសាលប្រជុំពិសេសក្រោម វិមានព្រឹទ្ធសភា។



❈នារសៀលថ្ងៃចន្ទ ទី១ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **អៀង ពីសី** និងឯកឧត្តម **កែវ សុម៉ាលី** នាយករងខុទ្ទកាល័យសម្តេចតេជោ ប្រធានព្រឹទ្ធសភា ព្រមទាំងសហការី បានអញ្ជើញនាំយកសាររំលែកមរណទុក្ខ ព្រមទាំងថវិការបស់សម្តេចតេជោ **ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ព្រមទាំងគោរពវិញ្ញាណក្ខន្ធសពឯកឧត្តមសាស្ត្រាចារ្យ **ហេង តៃគ្រី** រដ្ឋលេខាធិការក្រសួងសុខាភិបាល នៅសង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ៕



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ

ទូរសព្ទ៖ (855) 23 211 441, 211 442, 211 443 ទូរសារ៖ (855) 23 211 446

E-mail: secretariat@senate.gov.kh

www.senate.gov.kh www.elibrary.senate.gov.kh

senate of cambodia